# របាយការណ៍ប្រចាំឆ្នាំ
# ២០២៣-២០២៤







# មាតិកា

ពាក្យកាត់ ........................................................................................ ១
សាររបស់នាយិកាអង្គការឆេក .................................................................... ២
សាររបស់ក្រុមប្រឹក្សាភិបាលអង្គការឆេក ........................................................ ៤
អំពីអង្គការឆេក.......................................................................................... ៦
តំបន់គម្រោងសំខាន់ៗរបស់អង្គការឆេក........................................................ ៨
មេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា......................................................... ៩
ស្ថានភាពអំពើហិង្សាយេនឌ័រ........................................................................ ១០
សមិទ្ធិផលនៃកម្មវិធីបច្ចុប្បន្ន.......................................................................... ១២
ការផ្លាស់ប្តូរសំខាន់បំផុត................................................................................ ១៨
ម្ចាស់ជំនួយ .................................................................................................. ២០
របាយការណ៍ហិរញ្ញវត្ថុ.................................................................................. ២១
រចនាសម្ព័ន្ធអង្គការឆេកឆ្នាំ២០២៤ ............................................................... ២៣

# ពាក្យកាត់

| | |
|---|---|
| **AIDS** | ជំងឺអេដស៍ |
| **ART** | ការព្យាបាលប្រឆាំងមេរោគអេដស៍ដោយថ្នាំ |
| **ARV** | ថ្នាំប្រឆាំងមេរោគអេដស៍ |
| **BfdW** | Bread for the World |
| **CBE** | អ្នកអប់រំតាមសហគមន៍ |
| **CHEC** | អង្គការកម្ពុជាដើម្បីសុខភាព និងការអប់រំសហគមន៍ ( ឆេក ) |
| **CHR** | ការឆ្លើយតបសុខភាពសហគមន៍ |
| **CIP** | ផែនការវិនិយោគឃុំ |
| **GBV** | អំពើហឹង្សាយេនឌ័រ |
| **HC** | មណ្ឌលសុខភាព |
| **Misereor** | Misereor |
| **MoH** | ក្រសួងសុខាភិបាល |
| **MoWA** | ក្រសួងកិច្ចការនារី |
| **NAA** | អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ( National AIDS Authority ) |
| **NGO** | អង្គការមិនមែនរដ្ឋាភិបាល |
| **PLHIV** | អ្នកផ្ទុកមេរោគអេដស៍ |
| **SDGs** | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| **ODs** | ស្រុកប្រតិបត្តិ |
| **UN Trust Fund** | UN Trust Fund |
| **VCCT** | ការប្រឹក្សា និងការធ្វើតេស្តសម្ងាត់ដោយស្ម័គ្រចិត្ត |
| **YFC** | មជ្ឈមណ្ឌលមិត្តភាពយុវវ័យ |

# សាររបស់នាយិកាអង្គការឆេក



ជូនចំពោះអ្នកអាន!

ខ្ញុំមានសេចក្តីរីករាយក្នុងការបង្ហាញរបាយការណ៍ប្រចាំឆ្នាំស្តីពីលទ្ធផលនៃគម្រោងរបស់យើង។ ឆ្នាំនេះគឺជាជំហានដ៏អស្ចារ្យនៃការរីកចម្រើន ការរៀនសូត្រ និងការផ្លាស់ប្តូរដ៏មានឥទ្ធិពល។ ចាប់តាំងពីឆ្នាំ២០០១មក អង្គការឆេកបានក្លាយខ្លួនជាអង្គការក្នុងស្រុក និងបានចុះបញ្ជីជាអង្គការដែលមានឈ្មោះពេញគឺ "អង្គការកម្ពុជាដើម្បីសុខភាព និងការអប់រំសហគមន៍" ដែលធ្វើការផ្តោតទៅលើ ការចូលរួមសហគមន៍ ការអប់រំ ការបណ្តុះបណ្តាល ការតស៊ូមតិ និងកម្មវិធីគាំទ្រដែលផ្តោតលើជនរងគ្រោះ ជនងាយរងគ្រោះ រួមទាំងស្ត្រី កុមារ និងអ្នកផ្ទុកមេរោគអេដស៍។

ក្នុងរយៈពេល២៤ឆ្នាំកន្លងមកនេះ អង្គការឆេក បានមើលឃើញថា ការឆ្លើយតបដោយសហគមន៍ចំពោះដំណោះស្រាយគឺជាមធ្យោបាយប្រកបដោយនិរន្តរភាពបំផុតក្នុងការដោះស្រាយបញ្ហាប្រឈមសង្គម និងសុខភាពនៅក្នុងស្រុករបស់ពួកគេ។ ជាលទ្ធផល នៅតាមបណ្តាស្រុកដែលអង្គការឆេកមានសកម្មភាពនាពេលបច្ចុប្បន្ននេះ មានការបង្កើនទំនាក់ទំនងបន្ថែមជាមួយក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ គណៈកម្មាធិការគ្រប់គ្រងសុខភាព មន្ទីសុខាភិបាលខេត្ត និងអ្នកផ្តល់សេវាមូលដ្ឋាន។ ពួកយើងធ្វើការរួមគ្នាដើម្បីរៀបចំផែនការ និងអនុវត្តកម្មវិធីជាមួយសហគមន៍មូលដ្ឋាន។

បច្ចុប្បន្ននេះ អង្គការឆេកកំពុងដំណើរការគម្រោងចំនួនបី ក្នុងនោះមានគម្រោងលុបបំបាត់អំពើហិង្សាលើយេនឌ័រ ដែលមានអ្នកទទួលផលបានរហូតដល់៤៥០០នាក់។ គម្រោងនេះប្រើប្រាស់របៀបធ្វើការងារបែបការចូលរួមពហុភាគី ដែលផ្តោតទៅលើការផ្លាស់ប្តូរបទដ្ឋានសង្គម និងអាកប្បកិរិយាដែលទាក់ទងនឹងយេនឌ័រ រួមទាំងការកាត់បន្ថយ និងលុបបំបាត់អំពើហិង្សាលើស្ត្រី គាំទ្រស្ត្រី និងកុមារីដែលងាយរងគ្រោះ និងបង្កើនការផ្តល់សេវា និងការធ្វើអន្តរាគមន៍។ ចំពោះគម្រោងយុវវ័យដែលធ្វើការទៅលើការគាំទ្រក្រុមយុវវ័យដែលងាយរងគ្រោះ បានប្រើវិធីសាស្ត្រអន្តរាគមន៍ផ្អែកបឋម ក្នុងការធ្វើអោយប្រសើរឡើងនូវសមភាពយេនឌ័រ និងសុខភាព ដែលបានចូលរួមចំណែកជួយដល់ក្រុមងាយរងគ្រោះ អោយក្លាយទៅជាអ្នកបង្កើតការផ្លាស់ប្តូរបែបវិជ្ជមានទៅកាន់អ្នកជុំវិញខ្លួនរបស់គេ។ គម្រោងអប់រំសុខភាពឆ្លើយតបសហគមន៍គាំទ្រការផ្លាស់ប្តូរសុខភាពអាកប្បកិរិយាបែបវិជ្ជមានក្នុងចំណោមក្រុមស្ត្រីគោលដៅ និងជួយពួកគេពង្រឹងសហគមន៍តាមរយៈការការពារអំពើហិង្សា និងថែទាំសុខភាព។

គម្រោងខាងលើទាំងបីនេះ អង្គការឆេកបានចូលរួមចំណែកក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដូចជាគោលដៅទី៣ ផ្តោតលើសុខភាពល្អ និងសុខមាលភាព គោលដៅទី៤ ផ្តោតលើគុណភាពនៃការអប់រំ និងគោលដៅទី៥ ផ្តោតលើសមភាពយេនឌ័រ។ សម្រាប់ការចូលរួមក្នុងគោលដៅទី៤ អង្គការឆេកបានកំពុងធ្វើការជាមួយក្រុមយុវវ័យ ទាំងក្នុងនិងក្រៅសាលារៀន ដោយការបង្កើនការអប់រំអំពីសុខភាពបន្តពូជតាមរយៈមិត្តភក្តិយុវជននៅសហគមន៍។ កន្លងមក ការធ្វើសកម្មភាពតាមរយៈកម្មវិធីនេះរួមមានការអប់រំបែបសហគមន៍ ការជជែកពិភាក្សារបស់យុវវ័យ វេទិកាសហគមន៍ បានផ្តល់ឱកាសសម្រាប់យុវវ័យ ក្នុងនិងក្រៅសាលារៀន និងមនុស្សក្នុងសហគមន៍ក្នុងការបញ្ចេញមតិ និងទទួលយកការផ្លាស់ប្តូរអាកប្បកិរិយាទាក់ទងនឹងសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ ក៏ដូចជាសមភាពយេនឌ័រ។




ពួកយើងបានបង្កើនការចូលរួមដោយភាពស្មើគ្នា និងគ្មានការរើសអើងលើក្រុមគោលដៅ។ ពួកគេជាចំណែកមួយនៃដំណើរការអនុវត្តផែនការយុទ្ធសាស្ត្រនេះ។ ដើម្បីគាំទ្រដល់ការប្តេជ្ញាចិត្តផ្អែកលើសិទ្ធិមនុស្សរបស់របៀបវារៈការអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ក្រោមប្រធានបទ 'មិនទុកនរណាម្នាក់នៅពីក្រោយ' យើងបានគូសបញ្ជាក់ពីកង្វល់សិទ្ធិមនុស្សរបស់ស្ត្រី យុវជន ជនពិការ និងអ្នកមានមេរោគអេដស៍ និងជំងឺអេដស៍ ក្រុមអ្នកស្រលាញ់ភេទដូចគ្នា រួមទាំងអ្នកការពារសិទ្ធិ។

តាមរយៈការផ្តល់វគ្គបណ្តុះបណ្តាល អង្គការឆេកបានបង្កើតបណ្តាញអ្នកអប់រំសហគមន៍ រួមទាំងមេដឹកនាំយុវជន និងអាជ្ញាធរមូលដ្ឋាន ដើម្បីលើកកម្ពស់ការយល់ដឹងអំពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងកាត់បន្ថយការរិះគន់ទៅលើជនក្រីក្រ។ យុទ្ធនាការលើប្រព័ន្ធផ្សព្វផ្សាយសង្គម ព្រឹត្តិការណ៍ និងការជជែកពិភាក្សាជាសាធារណៈបានផ្លាស់ប្តូរផ្នត់គំនិតរបស់ពួកគេជាបន្តបន្ទាប់លើអំពើហិង្សាផ្អែកលើយេនឌ័រ និងទទួលស្គាល់ក្នុងការគោរពសិទ្ធិស្ត្រី និងបញ្ចប់ការបន្ទោសលើជនរងគ្រោះ។

លើសពីនេះ អង្គការឆេកបានបង្កើតមជ្ឈមណ្ឌលមិត្តអប់រំមិត្តដែលដឹកនាំដោយយុវជន ដើម្បីផ្តល់ការអប់រំសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ និងសិទ្ធិ ព្រមទាំងការបញ្ជូនបន្ត និងការប្រឹក្សាផងដែរ។ សកម្មភាពទាំងនេះផ្តោតលើមនុស្សដែលមានអត្តសញ្ញាណច្រើន ដូចជាក្រុមមនុស្សស្រលាញ់ភេទដូចគ្នា អ្នកផ្ទុកមេរោគអេដស៍ និងស្ត្រីមកពីក្រុមដែលមានប្រាក់ចំណូលទាបបំផុត។

តាមរយៈការបង្កើតក្រុមបញ្ជូនបន្តសម្រាប់ជនរងគ្រោះ អង្គការឆេកប្តេជ្ញាថាមិនទុកស្ត្រី ឬក្មេងស្រីដោយឡែកឡើយ។ ក្នុងរយៈពេលមួយឆ្នាំ បណ្តាញអ្នកអប់រំសហគមន៍បានបញ្ជូនស្ត្រីប្រហែល៤០០នាក់ទៅកាន់មណ្ឌលសុខភាព ក៏ដូចជាប៉ូលីស ដើម្បីស្វែងរកយុត្តិធម៌។

ការដែលអោយជនងាយរងគ្រោះដោយអំពើហិង្សា មានសិទ្ធិទទួលបានព័ត៌មាន និងចំណេះដឹង គឺជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពបំផុតនៃការពង្រឹងអំណាច ហើយពួកគេហ៊ានរាយការណ៍ទៅកាន់អ្នកគាំទ្រ និងអ្នកទទួលខុសត្រូវ។ មុនពេលគម្រោងនេះត្រូវបានបង្កើត ពួកគេមានភាពភ័យខ្លាចទៅលើជនល្មើស និងការមាក់ងាយពីសង្គម ប៉ុន្តែចាប់តាំងពីពួកគេបានចូលរួមក្នុងក្រុមស្ត្រីជួយខ្លួនឯង ពួកគេបានបន្តរៀនជំនាញក្នុងការចរចា និងការប្រាស្រ័យទាក់ទងដោយមិនប្រើហិង្សា។ នៅក្នុងការប្រជុំជាក្រុមពួកគេអាចចែករំលែកកង្វល់របស់ពួកគេ សួរសំណួរទៅកាន់អ្នកសម្របសម្រួលក្រុមដើម្បីស្វែងរកការគាំទ្រតាមវិធីសាស្ត្រជាច្រើន។ ពួកគេដឹងពីទីតាំងដែលផ្តល់សេវាជំនួយ។ អង្គការឆេកបានបើកកិច្ចប្រជុំប្រចាំត្រីមាសយ៉ាងទៀងទាត់ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីពិភាក្សាអំពីវឌ្ឍនភាព បញ្ហាប្រឈម និងមធ្យោបាយសម្រាប់ការកែលម្អបន្ថែមទៀតក្នុងការផ្តល់សេវា និងចែករំលែកបទពិសោធន៍ការងារល្អដល់គ្នាទៅវិញទៅមក។

នៅថ្នាក់ក្រោមជាតិ អង្គការឆេក បានបង្កើនការយល់ដឹងក្នុងចំណោមក្រុមយុវជន និងប្រជាពលរដ្ឋអំពីផលប៉ះពាល់អវិជ្ជមាននៃអំពើហិង្សាលើយេនឌ័រ។ ដូចគ្នានេះដែរ អង្គការបានផ្សារភ្ជាប់ជនងាយរងគ្រោះនិងអំពើហិង្សាលើយេនឌ័រ ជាមួយគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ និងក្រុមព្រឹក្សាឃុំសម្រាប់ស្ត្រីនិងកុមារ។

គម្រោងនេះត្រូវបានរៀបចំឡើងដើម្បីធានាថា ការធ្វើអន្តរាគមន៍ភាគច្រើននឹងមាននិរន្តរភាពតាមរយៈការវិនិយោគលើចំណេះដឹង ជំនាញ និងទំនុកចិត្តរបស់ក្រុមគោលដៅដែលជាអ្នកទទួលផល។ ខណៈពេលដែលគម្រោងនេះបានជួបនឹងបញ្ហាប្រឈមមួយចំនួន



អង្គការឆេកបានរៀបចំកម្មវិធីដ៏មានប្រសិទ្ធភាព ដើម្បីបន្តសម្រេចបាននូវគោលដៅរបស់ខ្លួន។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងកក់ក្តៅចំពោះម្ចាស់ជំនួយ ចំពោះការផ្តល់មូលនិធិរបស់ពួកគេ ក្នុងការផ្តល់ឱកាសជាច្រើនសម្រាប់ការធ្វើការងារនេះថ្ងៃទៅមុខទៀត។ វាជាការជំរុញ និងជាកាតាលីករសម្រាប់ការរីកចម្រើន និងការលូតលាស់ ដែលជំរុញអោយមានការប្តេជ្ញាចិត្ត លើកកម្ពស់តម្លាភាព ជួយកំណត់ផ្លូវដើរ លើកទឹកចិត្តដល់កិច្ចសហការ និងជំរុញអោយមានលទ្ធផលល្អ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រ និងថ្លែងអំណរគុណចំពោះសមាជិកក្រុមព្រឹក្សាភិបាលទាំងអស់សម្រាប់ការលះបង់របស់អ្នកចំពោះអង្គការឆេក។ តួនាទីនេះមានទំនួលខុសត្រូវយ៉ាងធំធេង ហើយអ្នកបានអនុវត្តតួនាទីនេះដោយបញ្ញាញាណ និងសុចរិតភាព។ ពេលវេលា និងការលះបង់ដែលអ្នកផ្តល់មកកាន់អង្គការឆេកក្នុងឆ្នាំនេះគឺអស្ចារ្យណាស់។

យើងនឹងបន្តពង្រីកកម្មវិធីរបស់យើង ធ្វើឱ្យការស្រាវជ្រាវរបស់យើងកាន់តែស៊ីជម្រៅ និងតស៊ូមតិសម្រាប់គោលនយោបាយដែលដោះស្រាយបញ្ហាឫសគល់នៃវិសមភាព។ គោលដៅរបស់ពួកយើងគឺបង្កើតសង្គមមួយដែលមានការរួមបញ្ចូល និងពោពេញទៅដោយសមធម៌កាន់តែច្រើន ដែលមនុស្សគ្រប់គ្នាមានឱកាសស្វែងរកភាពជោគជ័យ។

សរុបសេចក្តីមក ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមការងារ ដៃគូ និងសមាជិកសហគមន៍ដែលបានខិតខំប្រឹងប្រែង។ ការគាំទ្រ និងការសហការរបស់អ្នកមានសារៈសំខាន់ក្នុងភាពជោគជ័យរបស់យើង។ ទាំងអស់គ្នា យើងអាចធ្វើការរួមគ្នាដើម្បីភាពផ្លាស់ប្តូរ។

សូមអរគុណ។

**លោកស្រីបណ្ឌិត ភាសែម កុលណារី**
**នាយិកាប្រតិបត្តិ អង្គការឆេក**

# សាររបស់ប្រធានក្រុមប្រឹក្សាភិបាលអង្គការឆេក



អ្នកអានជាទីគោរព!

ខ្ញុំឈ្មោះ ផុន យុទ្ធសក្ការា ជាប្រធានក្រុមប្រឹក្សាភិបាលអង្ការឆេក ហើយខ្ញុំមានមោទនភាពដែលបានចែករំលែកជាមួយអ្នកនូវរបាយការណ៍ប្រចាំឆ្នាំរបស់អង្គការឆេក ចាប់ពីខែកក្កដា ឆ្នាំ២០២៣ ដល់ខែមិថុនា ឆ្នាំ២០២៤។

ក្នុងនាមខ្ញុំជាប្រធាន ខ្ញុំមានសេចក្តីសោមនស្សរីករាយក្នុងការរាយការណ៍អំពីសមិទ្ធផលដែលកើតចេញពីការអនុវត្តគម្រោងដោយបុគ្គលិកគម្រោងផ្ទាល់ និងអ្នកស្ម័គ្រចិត្តរបស់យើង។ ពួកគេបានធ្វើការដើម្បីផ្តល់ការគាំទ្រទៅដល់អ្នករស់នៅជាមួយមេរោគអេដស៍ អ្នករស់រានមានជីវិតពីអំពើហិង្សាលើយេនឌ័រនិងយុវជន។ ពួកគេក៏បានធ្វើការតស៊ូមតិជាមួយអ្នកដែលមានតួនាទីពាក់ព័ន្ធ ដើម្បីឱ្យពួកគេទទួលខុសត្រូវចំពោះកាតព្វកិច្ចរបស់ពួកគេក្នុងការលុបបំបាត់ការរើសអើង និងលើកកម្ពស់សមភាព។ តាមទស្សនៈសេដ្ឋកិច្ច កន្លែងដែលមានតម្រូវការកាន់តែច្រើន គួរតែមានការផ្គត់ផ្គង់កាន់តែច្រើន។ ជាលទ្ធផលនៃកិច្ចអន្តរាគមន៍របស់យើង យើងបានឃើញអ្នកដែលមានតួនាទីពាក់ព័ន្ធ បានផ្លាស់ប្តូរអាកប្បកិរិយារបស់ពួកគេ ឆ្លើយតបកាន់តែប្រសើរ និងរាយការណ៍អំពីបញ្ហារបស់ប្រជាពលរដ្ឋក្នុងផែនការនៃការអភិវឌ្ឍន៍មូលដ្ឋានរបស់ពួកគេ។ ជាប្រវត្តិសាស្ត្រ អង្គការឆេកគឺជាអង្គការក្រៅរដ្ឋាភិបាលដែលមានមូលដ្ឋាននៅខេត្ត និងក្នុងស្រុក។ យើងបានបង្កើតភាពជាដៃគូដ៏រឹងមាំជាមួយថ្នាក់មូលដ្ឋាននៅក្នុងកម្រិតវិស័យមេរោគអេដស៍/ជំងឺអេដស៍ អំពើហិង្សាលើយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់យុវជន។

អង្គការឆេក មានបទពិសោធន៍ខ្ពស់ក្នុងការពង្រឹងសមត្ថភាពយុវជន ស្ត្រី និងបុរស ដើម្បីធ្វើការរួមគ្នាជាមួយអាជ្ញាធរមូលដ្ឋាន។ យើងបានផ្សព្វផ្សាយព័ត៌មាន និងសេវាដល់សហគមន៍កាន់តែទូលំទូលាយ ក្រុមយុវជន និងក្រុមងាយរងគ្រោះ ដូច្នេះពួកគេអាចបន្តសកម្មភាពគម្រោងក្នុងសហគមន៍របស់ពួកគេថ្ងៃទៅមុខទៀត។ បុគ្គលិកអង្គការឆេក មានចំណេះដឹង និងបទពិសោធន៍ខ្ពស់ក្នុងការផ្តល់ការបណ្តុះបណ្តាលដល់ក្រុមគោលដៅទាំងនេះ អំពីភេទ យេនឌ័រ សុខភាពបន្តពូជ និងបំណិនជីវិត អស់រយៈពេលជាច្រើនឆ្នាំ។

អង្គការឆេកធ្វើការឆ្ពោះទៅរកនិរន្តរភាពនៃកម្មវិធីតាមរយៈការផ្តល់ការបណ្តុះបណ្តាល និងការចូលរួម និងការប្រមូលផ្តុំសហគមន៍។ នេះបង្កើតឲ្យមានភាពធន់លើខ្លួនឯង និងភាពជាម្ចាស់ការ ដើម្បីធ្វើការឆ្លើយតបទៅនឹងមេរោគអេដស៍ និងសុខភាពបន្តពូជផ្លូវភេទ អំពើហិង្សាលើយេនឌ័រ និងបញ្ហាផ្សេងៗ។ យើងគាំទ្រសហគមន៍ឱ្យចេះរៀបចំវគ្គអប់រំសហគមន៍ផ្ទាល់ខ្លួន និងមានភាពជាម្ចាស់ការនៃគំនិតផ្តួចផ្តើមរបស់ពួកគេ។

អង្គការឆេក ក៏ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសសម្រាប់ក្រុមប្រឹក្សាឃុំសម្រាប់ស្ត្រី និងកុមារដែលផ្តោតទៅលើតួនាទីសម្រាប់ពួកគេក្នុងការជួយស្ត្រីដែលងាយរងគ្រោះ ឬប្រឈមនឹងអំពើហិង្សាលើយេនឌ័រ និងការជួញដូរខុសច្បាប់។ យើងផ្តល់ជំនួយក្នុងការផ្សារភ្ជាប់ស្ត្រីទាំងនេះជាមួយ នឹងនគរបាល។ សមភាពយេនឌ័រគឺជាមូលដ្ឋាននៃសិទ្ធិមនុស្ស។ ស្ត្រីមានសិទ្ធិរស់នៅដោយសេចក្តីថ្លៃថ្នូរ និងសេរីភាព រួមទាំការរួចផុតពីសេចក្តីភ័យខ្លាច។ សមភាពយេនឌ័រក៏ជាលក្ខខណ្ឌមួយសម្រាប់ជំរុញការអភិវឌ្ឍន៍ និងកាត់បន្ថយភាពក្រីក្រផងដែរ។ ស្ត្រីដែលបានផ្តល់សិទ្ធិអំណាច បានរួមចំណែកផ្តល់នូវសុខភាព និងផលិតភាពនៃគ្រួសារ និងសហគមន៍ទាំងមូល ហើយពួកគេនឹងបន្តផ្តល់ការរំពឹងទុកសម្រាប់មនុស្សជំនាន់ក្រោយ។

គម្រោងនេះបានផ្សព្វផ្សាយយ៉ាងមានប្រសិទ្ធភាពនូវចំណេះដឹងអំពីការចម្លងមេរោគអេដស៍ក្នុងចំណោមយុវជន។ ជាលទ្ធផល ពួកគេបានចាប់ផ្តើមប្រើប្រាស់ស្រោមអនាម័យសម្រាប់ការពារមេរោគអេដស៍/ជំងឺអេដស៍ ដែលនឹងជាផលវិជ្ជមានល្អ និងសង្គមរបស់ពួកគេ។ លើសពីនេះ ដោយសារការកើនឡើងនៃការយល់ដឹង យុវជនអាចទទួលបានសេវាធ្វើតេស្តមេរោគអេដស៍ និងកាមរោគ។ អ្នកផ្ទុកមេរោគអេដស៍នៅតាមតំបន់គោលដៅកាន់តែមានការព្រួយបារម្ភអំពីបញ្ហា និងផលលំបាករបស់ពួកគេ។ កម្មវិធីមេរោគអេដស៍ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការវិនិយោគឃុំ និងផែនការអភិវឌ្ឍន៍ឃុំ ដើម្បីដោះស្រាយបញ្ហាប្រឈមរបស់អ្នកផ្ទុកមេរោគអេដស៍។ តាមរយៈការផ្តលសិទ្ធិអំណាចដល់អ្នកទទួលផល និងការកសាងការយល់ដឹងនៅក្នុងសហគមន៍ រួមជាមួយការចូលរួមពីអាជ្ញាធរមូលដ្ឋានដែលជាអ្នកពាក់ព័ន្ធ ការទទួលខុសត្រូវនៃការអនុវត្តគម្រោងត្រូវបានប្រគល់ទៅឱ្យក្រុមគោលដៅជាបន្តបន្ទាប់។ ការអនុវត្តន៍នេះ ធានានូវនិរន្តរភាពនៃគំនិតផ្តួចផ្តើមទាំងអស់។

បច្ចុប្បន្ននេះ អង្គការឆេកកំពុងដឹងនាំគម្រោងរយៈពេល៣ឆ្នាំ ដើម្បីដោះស្រាយបញ្ហាសំខាន់ៗចំនួន៣ ដែលអ្នករស់រានមានជីវិតពីអំពើហិង្សាលើយេនឌ័រប្រឈមមុខមានដូចជា ៖

- កង្វះការយល់ដឹងនៅក្នុងសហគមន៍ និងអាជ្ញាធរមូលដ្ឋានអំពីអំពើហិង្សាលើស្ត្រី និងកុមារ។
- ការប្រើប្រាស់សេវាពហុវិស័យសម្រាប់អ្នករស់រានមានជីវិតនៅមានកម្រិត
- គម្លាតក្នុងការអនុវត្តច្បាប់។

ជាលទ្ធផលនៃការរួមចំណែករបស់អង្គការឆេកក្នុងការឆ្ពោះទៅរកសមភាពយេនឌ័រ គឺជាការធ្វើឲ្យក្មេងស្រី និងក្មេងប្រុស ស្ត្រី និងបុរសទទួលបាននូវចំណេះដឹង គុណតម្លៃ អាកប្បកិរិយា និងជំនាញដើម្បីដោះស្រាយវិសមភាពយេនឌ័រ ដែលជាលក្ខខណ្ឌក្នុងការកសាងអនាគតប្រកបដោយចីរភាពសម្រាប់ទាំងអស់គ្នា។

លើសពីនេះ អង្គការឆេកបានបង្កើត និងជំរុញឲ្យមានទំនាក់ទំនងយ៉ាងរឹងមាំជាមួយក្រសួងកិច្ចការនារី ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល និងក្រសួងមហាផ្ទៃផងដែរ។ អង្គការឆេកក៏កំពុងសហការជាមួយអង្គការក្រៅរដ្ឋាភិបាល និងសកម្មជនសិទ្ធិមនុស្ស សិទ្ធិស្ត្រីផ្សេងទៀត ហើយពួកគេក៏កំពុងធ្វើការតស៊ូមតិជាមួយគណៈកម្មាធិការ CEDAW លើអនុសាសន៍ជាក់លាក់។

ក្នុងនាមខ្ញុំជាសាក្សី កិច្ចខិតខំប្រឹងប្រែងរបស់អង្គការឆេកក្នុងការជំរុញការផ្លាស់ប្តូរដ៏វិសេសវិសាលសម្រាប់ស្ត្រី និងកុមារកម្ពុជា ខ្ញុំអាចជម្រាបជូនអ្នកថា គម្រោងនេះកំពុងឈានទៅមុខដោយជោគជ័យក្នុងការសម្រេចបាននូវគោលបំណងទាំងអស់ និងបានបង្ហាញពីភាពពាក់ព័ន្ធបន្តរបស់ខ្លួនទៅនឹងតម្រូវការរបស់គោលដៅអ្នកទទួលផល។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបុគ្គលិកអង្គការទាំងអស់ និងថ្នាក់ដឹកនាំអង្គការឆេកសម្រាប់ការងារ និងការប្តេជ្ញាចិត្តរបស់ពួកគេក្នុងការការពារ និងផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងកុមារីឲ្យបទទួលបានសេវាសុខភាព និងការអប់រំក្នុងប្រទេសកម្ពុជា។ នៅក្នុងប្រទេសកម្ពុជា ស្ត្រីម្នាក់ក្នុងចំណោមប្រាំនាក់បានជួបប្រទះអំពើហិង្សាលើរាងកាយយ៉ាងហោចណាស់ម្តង[១] ការងារពហុភាគីដែលដឹកនាំដោយ អង្គការឆេក ដៃគូ និងបណ្តាញរបស់ខ្លួន កំពុងបង្កើតឲ្យមានការផ្លាស់ប្តូរជាក់ស្តែង និងនិរន្តរភាពនៅក្នុងសហគមន៍មូលដ្ឋាន។

ជាចុងក្រោយ យើងខ្ញុំសូមថ្លែងអំណរគុណ និងថ្លែងអំណរគុណចំពោះម្ចាស់ជំនួយ អ្នកគាំទ្រ អ្នកស្ម័គ្រចិត្ត និងសមាជិកក្រុមប្រឹក្សាភិបាលសម្រាប់ការប្តេជ្ញាចិត្តដ៏រឹងមាំ និងមុះមុតរបស់ពួកគេ តាមរយៈយុទ្ធសាស្ត្រ និងគោលនយោបាយផ្សេងៗរបស់អង្គការឆេក ក្នុងការអភិវឌ្ឍន៍ស្ថាប័ន ដោយសម្រេចបាននូវជំហានដ៏ធំធេង។

សូមអរគុណចំពោះការចំណាយពេលអានរបាយការណ៍ប្រចាំឆ្នាំនេះ។



**លោកផុន យុទ្ធសក្តារា**
**ប្រធានក្រុមប្រឹក្សាភិបាល អង្គការឆេក**



ជាប្រវត្តិសាស្ត្រ អង្គការឆេកគឺជាអង្គការមិនមែនរដ្ឋាភិបាល ដែលមានមូលដ្ឋាននៅតាមខេត្ត។ យើងកសាងភាពជាដៃគូរឹងមាំជាមួយរដ្ឋាភិបាលមូលដ្ឋាននៅគ្រប់កម្រិតទាំងអស់ក្នុងវិស័យមេរោគអេដស៍/ជំងឺអេដស៍ អំពើហិង្សាលើយេនឌ័រ និងយុវជន។ រយៈពេល៣ឆ្នាំខាងមុខ អង្គការឆេកនឹងបន្តការងារនៅក្នុងខេត្តចំនួន៥គឺ ខេត្តព្រៃវែង កំពង់ឆ្នាំង កំពត កំពង់ចាម និងកណ្តាល។

អង្គការឆេកក៏នឹងបន្តធ្វើការនៅក្នុងស្រុកបច្ចុប្បន្ន ហើយនឹងពង្រីកទៅស្រុកថ្មីចំនួន២គឺ ស្រុកជុំគីរី និងកៀនស្វាយ ជាមួយគម្រោងយុវជន និងគម្រោងអំពើហិង្សាលើយេនឌ័រ និងស្រុកថ្មីចំនួន២ទៀតគឺ ស្រុកសាមគ្គីមានជ័យ និងស្រុកពារាំង ជាមួយគម្រោងសុខភាពឆ្លើយតបសហគមន៍។ ដែលជារួម យើងកំពុងធ្វើការជាមួយមណ្ឌលសុខភាពចំនួន៦១ ៧៩ឃុំ និង៥៦៦ភូមិ នៅក្នុងស្រុកទាំង៨ ក្នុងចំណោមខេត្តទាំង៥។




# អំពីអង្គការឆេក



ដោយសារកេរ្តិ៍ឈ្មោះរបស់ខ្លួនក្នុងការងារអេដស៍ និងជំងឺអេដស៍នៅកម្ពុជា អង្គការឆេកបានពង្រឹងសមត្ថភាពរបស់ខ្លួនក្នុងការអភិវឌ្ឍគម្រោងអំពើហិង្សាលើយេនឌ័រ នៅក្នុងស្រុកគោលដៅចំនួន៤ ទូទាំង៤ខេត្ត។ វិសាលភាពនៃការងាររបស់ខ្លួនធ្វើឱ្យ ពួកយើងជាអង្គការក្នុងស្រុកដំបូងគេដែលរួមបញ្ចូល អំពើហិង្សាលើយេនឌ័រ និងមេរោគអេដស៍/ជំងឺអេដស៍រួមគ្នា។ អ្វីដែលអង្គការឆេកធ្វើ គឺដើម្បីផ្តល់ជាមធ្យោបាយ និង ដំណោះស្រាយដើម្បីដោះស្រាយអំពើហិង្សាលើយេនឌ័រនៅប្រទេសកម្ពុជា។ នៅថ្នាក់ជាតិ អង្គការឆេកគឺជាសមាជិកនៃក្រុមការងារបច្ចេកទេសយេនឌ័ ក្រោមការសម្របសម្រួលរបស់ក្រសួងកិច្ចការនារីសម្រាប់ការអនុវត្តន៍ផែនការជាតិស្តីពីអំពើហិង្សាលើស្ត្រី។

## ទស្សនវិស័យ

ទាំងអស់គ្នារស់នៅក្នុងសេចក្តីថ្លៃថ្នូរ សុខុមាលភាព និងការចូលរួមដោយស្មើភាព

## បេសកកម្ម

អង្គការឆេក មានគោលបំណងផ្តល់សិទ្ធិអំណាចដល់យុវជន អ្នករស់រានមានជីវិតពីអំពើហិង្សាលើយេនឌ័រ និងអ្នកផ្ទុកមេរោគអេដស៍តាមរយៈការសហការជាមួយភាគីពាក់ព័ន្ធក្នុងតំបន់ ដើម្បីរក្សាបានការចូលរួមស្មើៗគ្នា រួមទាំងសុខុមាលភាព និងសេចក្តីថ្លៃថ្នូររបស់ក្រុមគោលដៅ។

## ទិសដៅ

ក្នុងរយៈពេល 3 ឆ្នាំខាងមុខ អង្គការឆេកនឹងបានលើកកម្ពស់សិទ្ធិស្មើគ្នា និងការចូលរួមយ៉ាងសកម្មក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តរបស់ក្រុមគោលដៅ តាមរយៈការប្រើប្រាស់យុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាព។

## គុណតម្លៃ

**កិច្ចសហការ៖** យើងជឿជាក់ថា ការអភិវឌ្ឍន៍ និងការរក្សាទំនាក់ទំនង ការគោរពគ្នាទៅវិញទៅមកពី បុគ្គល សហគមន៍ អង្គការដៃគូ ម្ចាស់ជំនួយ និងអ្នកពាក់ព័ន្ធផ្សេងទៀត គឺជាលទ្ធផលល្អបំផុតនៃកិច្ចសហប្រតិបត្តិការ និងការធ្វើការងារជាក្រុម។

**សមភាពយេនឌ័រ៖** យើងជឿថាមនុស្សគ្រប់រូបត្រូវតែមានឱកាសស្មើគ្នា និងទទួលបានអត្ថប្រយោជន៍ស្មើគ្នាពីការអភិវឌ្ឍន៍ ដោយមិនគិតពីភេទ សាសនា ជនជាតិដើមភាគតិច ឬជនមានពិការភាព។ ស្ត្រីនិងក្មេងស្រីមិនអាចទុកចោលបានទេ។

**ការចូលរួមដោយស្មើភាពគ្នា៖** យើងជឿថាមនុស្សទាំងអស់គួរតែមានការបញ្ចេញមតិនៅក្នុងបញ្ហាដែលប៉ះពាល់ដល់ជីវិតរបស់ពួកគេ រួមទាំងស្ត្រី ក្មេងស្រី និងក្រុមមនុស្សដែលងាយរងគ្រោះ។

**ការប្តេជ្ញាចិត្ត៖** យើងជឿជាក់ថាធនធានទាំងអស់ដែលយើងបានវិនិយោគ នឹងជួយកាត់បន្ថយការរើសអើងទៅលើក្រុមស្ត្រីដែលងាយរងគ្រោះ និងកូនរបស់ពួកគេ ហើយរួមចំណែកដល់ការលើកកម្ពស់សិទ្ធិទទួលបាន និងឱកាសស្មើគ្នា ការបញ្ចេញមតិ និងជម្រើសនៅក្នុងការសម្រេចចិត្តទាំងអស់ដែលប៉ះពាល់ដល់ពួកគេ។

**ទំនួលខុសត្រូវ៖** យើងជឿថាយើងបានឆ្លើយតប និងទទួលខុសត្រូវចំពោះស្ត្រី និងកុមារជុំវិញគេនៅក្នុងប្រទេសកម្ពុជា។ យើងក៏ទទួលស្គាល់ពីសារៈសំខាន់នៃការឆ្លើយតបចំពោះរដ្ឋាភិបាល ម្ចាស់ជំនួយរបស់យើង និងរវាងគ្នាទៅវិញទៅមក។

# តំបន់គម្រោងសំខាន់ៗរបស់អង្គការឆេក




បច្ចុប្បន្នអង្គការឆេក កំពុងដំណើរការនៅក្នុងខេត្តចំនួន៥ ស្រុកចំនួន៨ផ្សេងគ្នានៅទូទាំងប្រទេសកម្ពុជា។ ក្នុងនោះមាន ៥៦៦ភូមិ និង ៧៩ឃុំនៅទូទាំងប្រទេស។ ខេត្តទាំងនេះមានដូចជា ខេត្តព្រៃវែង ខេត្តកំពង់ឆ្នាំង ខេត្តកំពត ខេត្តកំពង់ចាម និង ខេត្តកណ្តាល ដែលផ្តោតលើយុវជន អំពើហិង្សាយេនឌ័រ ឬការថែទាំតាមសហគមន៍ទាំងស្រុង រួមបញ្ចូលគ្នា។ ជាក់ស្តែង ក្នុងខេត្តកំពង់ចាមយើងអនុវត្តគម្រោងគោលដៅទាំងបី ចំណែកខេត្តព្រៃវែងអនុវត្តតែគម្រោងទាក់ទងនឹងការថែទាំសហគមន៍ប៉ុណ្ណោះ។ ខាងក្រោមនេះជាផែនទីប្រទេសកម្ពុជា ដែលបង្ហាញពីតំបន់គម្រោងរបស់អង្គការឆេក។

**ខេត្តកំពង់ឆ្នាំង**

ស្រុកបរិបូណ៌
ស្រុកកំពង់ត្រឡាច
ស្រុកសាមគ្គីមានជ័យ

**ខេត្តកំពង់ចាម**

ស្រុកស្រីសន្ធរ

**ខេត្តព្រៃវែង**

ស្រុកពាមជរ
ស្រុកពារាំង

**ខេត្តកំពត**

ស្រុកជុំគិរី

**ខេត្តកណ្តាល**

ស្រុកកៀនស្វាយ

៥ ខេត្ត
៨ ស្រុក
៥០០+ភូមិ







# តំបន់គម្រោងសំខាន់ៗរបស់អង្គការឆេក




បច្ចុប្បន្នអង្គការឆេក កំពុងដំណើរការនៅក្នុងខេត្តចំនួន៥ ស្រុកចំនួន៨ផ្សេងគ្នានៅទូទាំងប្រទេសកម្ពុជា។ ក្នុងនោះមាន ៥៦៦ភូមិ និង ៧៩ឃុំនៅទូទាំងប្រទេស។ ខេត្តទាំងនេះមានដូចជា ខេត្តព្រៃវែង ខេត្តកំពង់ឆ្នាំង ខេត្តកំពត ខេត្តកំពង់ចាម និង ខេត្តកណ្ដាល ដែលផ្តោតលើយុវជន អំពើហិង្សាយេនឌ័រ ឬការថែទាំតាមសហគមន៍ទាំងស្រុង រួមបញ្ចូលគ្នា។ ជាក់ស្តែង ក្នុងខេត្តកំពង់ចាមយើងអនុវត្តគម្រោងគោលដៅទាំងបី ចំណែកខេត្តព្រៃវែងអនុវត្តតែគម្រោងទាក់ទងនឹងការថែទាំសហគមន៍ប៉ុណ្ណោះ។ ខាងក្រោមនេះជាផែនទីប្រទេសកម្ពុជា ដែលបង្ហាញពីតំបន់គម្រោងរបស់អង្គការឆេក។

**ខេត្តកំពង់ឆ្នាំង**
ស្រុកបរិបូណ៌
ស្រុកកំពង់ត្រឡាច
ស្រុកសាមគ្គីមានជ័យ

**ខេត្តកំពង់ចាម**
ស្រុកស្រីសន្ធរ

**ខេត្តព្រៃវែង**
ស្រុកពាមជរ
ស្រុកពារាំង

**ខេត្តកំពត**
ស្រុកជុំគិរី

**ខេត្តកណ្ដាល**
ស្រុកកៀនស្វាយ

៥ ខេត្ត
៨ ស្រុក
៥០០+ភូមិ







# មេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា

ប្រទេសកម្ពុជាមានឈ្មោះជាផ្លូវការថា ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសកសិកម្ម ដែលមានផ្ទៃដីសរុប ១៨១ ០៣៥ គីឡូម៉ែត្រក្រឡា(៦៩ ៨៩៨ ម៉ៃត្រការ៉េ) និងមានព្រំប្រទល់ជាប់ប្រទេសថៃខាងលិចឈៀងខាងជើង ជាប់សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវនៅភាគឦសាន ជាប់ប្រទេសវៀតណាមភាគខាងកើត និងឈូងសមុទ្រថៃភាគនិរតី។ ប្រទេសកម្ពុជាមានប្រជាជនសរុបជិត ១៦លាននាក់។ ភាគច្រើន(ប្រហែល៧៥%) នៃប្រទេសស្ថិតនៅលើកម្ពស់តិចជាង ១០០ម៉ែត្រ(៣៣០ហ្វីត) ពីលើនីវ៉ូទឹកសមុទ្រ លើកលែងតែភ្នំក្រវាញ ដែលមានកម្ពស់ខ្ពស់បំផុត ១៨១៣ម៉ែត្រ(៥៩៤៨ហ្វីត) និងជួរភ្នំរបស់វា។

ប្រជាជនកម្ពុជាដែលបានប៉ាន់ស្មានក្នុងខែមករាឆ្នាំ២០២១ មានចំនួន ១៥.៥លាននាក់ ក្នុងនោះស្ត្រី៥១.៤% និងបុរស៤៨.៥% ជាមួយនឹងអាត្រាកំណើនប្រជាជនជាប្រចាំឆ្នាំ ១.៤៦%។ ប្រជាជនប្រហែល៨០%រស់នៅក្នុងតំបន់ជនបទ។ ទោះជាយ៉ាងណាក៏ដោយ ការធ្វើចំណាកស្រុកពីជនបទទៅទីក្រុងបានកើនឡើងយ៉ាងឆាប់រហ័សក្នុងទសវត្សរ៍ចុងក្រោយនេះ។ អាត្រាកំណើតប្រជាជនក្នុងអាត្រា ១.៨% ស្ថិតនៅលំដាប់ទី២បន្ទាប់ពីប្រទេសឡាវក្នុងចំណោមប្រទេសអាស៊ាន។ ប្រជាជនជាង៣៨% ស្ថិតនៅក្រោមអាយុ១៥ឆ្នាំ។ ទោះជាយ៉ាងណាក៏ដោយ អាត្រាកំណើតបានថយចុះយ៉ាងខ្លាំងពី២.៤% ក្នុងឆ្នាំ១៩៩៨។ ចំពោះជាតិសាសន៍វិញ ប្រហែល ៩០% នៃចំនួនប្រជាជន ជាជនជាតិខ្មែរ ខណៈដែល ១០% ជាជនជាតិមានដូចជា ជនជាតិដើមភាគតិច ចាម ជនជាតិចិន និងវៀតណាម។ ក្នុងនោះប្រហែល ៩៥% ប្រើប្រាស់ភាសាខ្មែរ។

ទន្ទឹមនឹងការថយចុះនៃចំណេះដឹងអំពីមេរោគអេដស៍/ជំងឺអេដស៍ ដៃគូអភិវឌ្ឍន៍ក៏បានកាត់បន្ថយអាទិភាពរបស់ពួកគេក្នុងការគាំទ្រកម្មវិធីបង្ការ ជាពិសេសក្នុងការអប់រំផ្ទាល់ដល់ក្រុមគោលដៅ។ កម្ពុជាប្តេជ្ញាធ្វើការជាមួយប្រទេសដែលជាសមាជិកអង្គការសហប្រជាជាតិទាំងអស់ ដើម្បីកំណត់គោលដៅនៃការបញ្ចប់ជំងឺអេដស៍នៅឆ្នាំ២០២៥ សម្រាប់កម្ពុជាដើម្បីធានាថាប្រជាជនកម្ពុជារស់នៅដោយសុខសាន្ត និងគ្មានការគម្រាមកំហែងពីមេរោគអេដស៍/ជំងឺអេដស៍ តាមរយៈកិច្ចខិតខំប្រឹងប្រែងដើម្បីគ្រប់គ្រងការចម្លងមេរោគអេដស៍/ជំងឺអេដស៍ឱ្យបានពេញលេញ និងធ្វើឱ្យមេរោគអេដស៍/ជំងឺអេដស៍ក្លាយជាបញ្ហាសុខភាពសាធារណៈ។




ដើម្បីសម្រេចបាននូវ គោលដៅនេះរាជរដ្ឋាភិបាលកម្ពុជាបានសម្រេចបង្កើតគោលនយោបាយជាតិដើម្បីបញ្ចប់ជំងឺអេដស៍នៅឆ្នាំ២០២៥ និងនិរន្តភាពមេរោគអេដស៍ឆ្នាំ២០២៣-២០២៨ ដើម្បីធានាបាននៅបរិយាកាសអំណោយផលក្នុងការសម្រួលដល់ការឆ្លើយតប នឹងមេរោគអេដស៍/ជំងឺអេដស៍ពហុវិស័យប្រកបដោយភាពរលូន និងប្រសិទ្ធភាព ដោយជំរុញឱ្យមានការចូលរួមដោយទូលំទូលាយពីគ្រប់ភាគីពាក់ព័ន្ធក្នុងយន្តការ នៅក្នុងសង្គមតែមួយ និងគោលការណ៍សិទ្ធិមនុស្សតែមួយ ដើម្បីបញ្ចប់ការរើសអើង និងការមាក់ងាយក្នុងការផ្តល់ និងការទទួលបានសេវាបង្ការ ការថែទាំ ការព្យាបាល និងការគាំទ្រសម្រាប់ក្រុមគោលដៅទាំងអស់។

# ស្ថានភាពទូទៅអំពើហិង្សាលើយេនឌ័រ

នៅកម្ពុជាក្នុងឆ្នាំ២០២២ យោងតាមការរកឃើញថ្មីៗរបស់ CDHS ២០២១-២០២២ បានបង្ហាញពីលទ្ធភាពនៃអំពើហិង្សាដែលបង្កដោយស្វាមី/ដៃគូជិតស្និតក្នុងរយៈពេល១២ខែចុងក្រោយនេះ កើនឡើងតាមអាយុរបស់ស្ត្រី ក្នុងនោះ ៩%នៃស្ត្រីដែលមានអាយុពី ១៥-១៩ឆ្នាំ បានរាយការណ៍ថាបានជួបប្រទះអំពើហិង្សាផ្លូវកាយ ផ្លូវភេទ ឬផ្លូវអារម្មណ៍ដោយស្វាមី/ដៃគូជិតស្និត បើធៀបនឹង ១៧%នៃស្ត្រីដែលមានអាយុពី ៤០-៤៩ឆ្នាំ។ ១៦%នៃស្ត្រីនៅតំបន់ជនបទបានរាយការណ៍ថា បានជួបប្រទះនូវទម្រង់នៃអំពើហិង្សាលក្ខណៈដៃគូជិតស្និតក្នុងរយៈពេល១២ខែចុងក្រោយពីស្វាមី/ដៃគូជិតស្និត បើធៀបនឹង ៩%នៃស្ត្រីនៅក្នុងតំបន់ទីក្រុង។ ស្ថានភាពរបស់ស្ត្រីក្នុងការជួបប្រទះអំពើហិង្សាលក្ខណៈដៃគូជិតស្និតដោយស្វាមី/ដៃគូជិតស្និតណាមួយក្នុងរយៈពេល១២ខែចុងក្រោយនេះបានធ្លាក់ចុះយ៉ាងខ្លាំងដោយសារការទទួលបានការអប់រំ។ ភាគរយនៃស្ត្រីដែលបានជួបប្រទះនឹងអំពើហិង្សាផ្លូវកាយ ផ្លូវភេទ ឬផ្លូវចិត្តពីស្វាមី/ដៃគូជិតស្និតក្នុងរយៈពេល១២ខែចុងក្រោយនេះថយចុះពី ២០%ក្នុងចំណោមអ្នកដែលគ្មានការអប់រំមកត្រឹម ៣%ក្នុងចំណោមអ្នកដែលមានការអប់រំលើសពីមធ្យមសិក្សា។ ស្រដៀងគ្នានេះដែរភាគរយនៃស្ត្រីដែលបានជួបប្រទះផ្លូវកាយ ផ្លូវភេទ ឬផ្លូវចិត្តពីស្វាមី/ដៃគូជិតស្និតណាមួយបានថយចុះពី ២២%ក្នុងចំណោមអ្នកដែលមានទ្រព្យសម្បត្តិទាបបំផុតដល់ ៦%ក្នុងចំណោមអ្នកដែលមានទ្រព្យសម្បត្តិខ្ពស់បំផុត។






ការទទួលបានការអប់រំ រួមទាំងការអប់រំផ្លូវភេទគ្រាប់ជ្រុងជ្រោយ និងសេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជមានសារៈសំខាន់ណាក្នុងការគាំទ្រស្វ័យភាពរបស់ស្ត្រី និងកុមារី។ នៅពេលដែលស្ត្រីត្រូវបានផ្តល់សិទ្ធិអំណាចក្នុងការសម្រេចចិត្ត ពួកគេទំនងជាមានការចរចារួមភេទដោយសុវត្ថិភាពជាងមុន មានចំណេះដឹងទាក់ទងនឹងមេរោគអេដស៍ខ្ពស់ និងចេះប្រើស្រោមអនាម័យ។ លើសពីនេះ ការរួមបញ្ចូលសេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជជាមួយនឹងសេវាសុខភាពផ្សេងទៀតធ្វើឱ្យមានការប្រសើរឡើងក្នុងការទទួលបាន ឧទាហរណ៍ ជំងឺរបេង និងការពិនិត្យមហារីកមាត់ស្បូន ការការពារ និងការព្យាបាល និងកាត់បន្ថយផលប៉ះពាល់នៃអំពើហិង្សាលើយេនឌ័រ។ ស្ត្រី និងកុមារីនៅក្នុងប្រទេសកម្ពុជា ងាយរងគ្រោះដោយអំពើហិង្សា។ ក្នុងឆ្នាំ២០១៥ ២១%នៃស្ត្រីដែលមិនធ្លាប់មានដៃបានជួបប្រទះអំពើហិង្សាផ្លូវកាយ និង/ឬផ្លូវភេទដោយដៃគូ ខណៈដែល ៨%បានរាយការណ៍ថាបានជួបប្រទះអំពើហិង្សាលើរាងកាយ និង/ឬផ្លូវភេទក្នុងរយៈពេល១២ខែចុងក្រោយនេះ។ នៅឆ្នាំ២០២២ ការរកឃើញថ្មីៗបង្ហាញថា បានថយចុះមកត្រឹម ១០% និង៥.៤%។

យោងតាមការស្ទង់មតិ និងសុខភាពកម្ពុជាឆ្នាំ ២០២១-២០២២ ភាគរយនៃស្ត្រីដែលជួបប្រទះអំពើហិង្សាពីដៃគូជិតស្និតមួយ ឬច្រើន ជាទូទៅកើនឡើងតាមអាយុ។ ស្ត្រីនៅតាមតំបន់ជនបទទំនងជាទទួលរងនូវអំពើហិង្សាផ្លូវកាយ ផ្លូវភេទ ឬផ្លូវចិត្តដោយស្វាមីឬដៃគូជិតស្និតបច្ចុប្បន្ន ឬចុងក្រោយបំផុតរបស់ពួកគេជាជាងស្ត្រីដែលនៅទីក្រុង(២៣%ធៀបនឹង១៧%)។ តាមខេត្ត ភាគរយនៃស្ត្រីដែលរៀបការហើយដែលធ្លាប់ទទួលរងអំពើហិង្សាផ្លូវកាយ ផ្លូវភេទ ឬផ្លូវចិត្តដោយស្វាមីឬដៃគូជិតស្និតបច្ចុប្បន្ន ឬចុងក្រោយបំផុតដែលទាបបំផុតគឺខេត្តកោះកុង ៦% និងខ្ពស់បំផុតគឺខេត្តមណ្ឌលគិរី ៤៥%។

នៅតាមបណ្តាខេត្តគោលដៅរបស់អង្គការឆេក មានភាគរយនៃស្ត្រីដែលរៀបការហើយដែលបានជួបប្រទះអំពើហិង្សាផ្លូវកាយ ផ្លូវភេទ ឬផ្លូវចិត្តដោយស្វាមីឬដៃគូជិតស្និតបច្ចុប្បន្ន ឬចុងក្រោយបំផុតរបស់ពួកគេ ១៩%ក្នុងខេត្តកំពង់ឆ្នាំង និង២៦% នៅខេត្តព្រៃវែង។
ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រី ក៏បានបង្កើតបណ្តាញសេវាច្រកចេញចូលតែមួយសម្រាប់ស្ត្រីរងគ្រោះដោយអំពើហិង្សានៅក្នុងខេត្តចំនួន៤ និងស្រុកចំនួន៣៩។ ពហុសេវានេះបង្កើតឡើង ដើម្បីជួយជនរងគ្រោះ ដែលមាននៅក្នុងមន្ទីរពេទ្យចំនួន៤គឺ កំពង់ចាម ស្ទឹងត្រែង ត្បូងឃ្មុំ និងព្រះវិហារ ហើយបន្តពង្រីកដល់រាជធានីភ្នំពេញ និងបាត់ដំបង។





នៅខែមេសា ឆ្នាំ២០២៤ ក្រសួងកិច្ចការនារីបានដាក់ឱ្យដំណើរការជាផ្លូវការ “ផែនការយុទ្ធសាស្ត្រនារីរតនៈលើកទី៦(២០២៤-២០២៨)” ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងផ្តល់សិទ្ធិអំណាចដល់ស្ត្រីស្របតាមយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាល។
នារីរតនៈទី៦ មានចក្ខុវិស័យ «ប្រជាពលរដ្ឋគ្រប់រូប បុរស ស្ត្រី កុមារា និងកុមារី មានសិទ្ធិស្មើគ្នា សុវត្ថិភាព ការចូលរួមពេញលេញក្នុងការងារសង្គម ភាពជឿជាក់លើខ្លួនឯង និងភាពជាអ្នកដឹកនាំ និងសមភាព ដើម្បីទទួលបានសុខុមាលភាពក្នុងគ្រួសារ សហគមន៍ និងសង្គម»យោងតាមប្រសាសន៍របស់រដ្ឋមន្ត្រី។



# សមិទ្ធិផល នៃកម្មវិធី បច្ចុប្បន្ន



កំពង់ឆ្នាំង កម្ពុជា។ សិស្សស្រីម្នាក់កំពុងនិយាយក្នុងទិវាប្រយុទ្ធប្រឆាំងនឹងជម្ងឺអេដស៍

# គម្រោង៖ ការផ្ដល់អំណាចដល់យុវជន សម្រាប់សុខភាពផ្លូវភេទ សុខភាពបន្តពូជ និងសិទ្ធិ និងការចូលរួមក្នុងសហគមន៍/ការតស៊ូមតិ សម្រាប់ការអប់រំក្នុងសហគមន៍ ដើម្បីបញ្ចប់អំពើហិង្សាលើស្ត្រី

អង្គការឆេកធ្វើការជាមួយការឆ្លើយតបដែលជំរុញដោយសហគមន៍ចំពោះបញ្ហាប្រឈមនៅក្នុងសង្គម និងបញ្ហាសុខភាព។ បច្ចុប្បន្នយើងមានសកម្មភាពក្នុងស្រុកចំនួន៨ ក្នុងខេត្តចំនួន៥ក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ។ យើងបានបង្កើតកេរ្តិ៍ឈ្មោះជាអ្នកផ្ដល់សេវាដ៏គួរឱ្យទុកចិត្ត និងមានប្រសិទ្ធភាពសម្រាប់សុខភាពយុវជនស្ម័គ្រចិត្ត និងស្ត្រីឲ្យមានការយល់ដឹងអំពីសិទ្ធិរបស់ពួកគេកាលពីប៉ុន្មានឆ្នាំមុន។ យុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពបំផុតគឺភាពជាដៃគូជាមួយប្រព័ន្ធផ្ដល់សេវារបស់រដ្ឋាភិបាល ដែលបានសង្កត់ធ្ងន់គឺលើការកសាងសមត្ថភាព និងការប្តេជ្ញាចិត្តចំពោះសកម្មភាពរបស់មន្ត្រីរាជការសាធារណៈមានដូចជាថ្នាក់ក្រោមជាតិ និងសហគមន៍។

អង្គការឆេក សូមកោតសរសើររចនាសម្ព័ន្ធទាំងនេះដោយការកសាង និងពង្រឹងអ្នកស្ម័គ្រចិត្តក្នុងសហគមន៍ និងយុវជនតាមរយៈប្រព័ន្ធមិត្តអប់រំមិត្ត។ បុគ្គលិកគម្រោងរបស់យើងបានធ្វើការសម្របខ្លួន ទទទួលយកវិធីសាស្ត្រដែលបានបង្ហាញឱ្យឃើញអំពីការអប់រំសហគមន៍ និងការកៀរគរ។ ជំនាញដែលបានរៀនទាំងនេះដែលមានដូចជា ការសម្របសម្រួល យុទ្ធនាការផ្សព្វផ្សាយព័ត៌មាន ការស្រាវជ្រាវដោយមានការចូលរួម ការគ្រប់គ្រងភ័ស្តុភារ និងការអប់រំដ៏ល្អនេះ អាចឱ្យពួកគេធ្វើសកម្មភាពទៅតម្រូវការរបស់សហគមន៍ពួកគេ។

ការកសាងបណ្តាញសហគមន៍ បានបម្រើជាកម្មវិធីមូលដ្ឋាននៃសេវាកម្មដែលត្រូវបានចែកចាយប្រកបដោយប្រសិទ្ធភាព។

យុវជនកម្ពុជាត្រូវបានប៉ះពាល់ជាពិសេសចំពោះភាពងាយរងគ្រោះ នៅក្នុងបរិបទនៃភាពក្រីក្រ ភាពទន់ខ្សោយខាងរាងកាយ និងផ្លូវចិត្ត អំពើហិង្សា និងការរំលោភបំពាន និងការធ្វើចំណាកស្រុក។ បើនិយាយពីភាពក្រីក្រ និងការមើលរំលងនៅក្នុងសង្គម យុវជនកម្ពុជា ៣៦%ស្ថិតនៅក្រោមបន្ទាត់នៃភាពក្រីក្រ។ ការប្រឈមមុខនឹងបញ្ហាសុខភាពផ្លូវកាយ និងផ្លូវចិត្ត កង្វះលទ្ធភាពទទួលបានតម្រូវការមូលដ្ឋាន ភាពឯកោ និងគ្រោះថ្នាក់ដូចជា ការកេងប្រវ័ញ្ចផ្លូវភេទ កុមារតាមចិញ្ចើមផ្លូវ កុមារកំព្រា និងជនចំណាកស្រុកវ័យក្មេង គឺជាក្រុមដែលងាយរងគ្រោះបំផុត។ ការធ្វើចំណាកស្រុកពីជនបទទៅទីក្រុង និងឆ្លងដែនដើម្បីស្វែងរកឱកាសការងារ គឺជារឿងទូរទៅក្នុងចំណោមយុវជនកម្ពុជា។

អង្គការឆេកធ្វើការយ៉ាងទូលំទូលាយនៅក្នុងសហគមន៍មូលដ្ឋាន ដើម្បីកែលម្អសេវាថែទាំសេវាសុខភាព និងការគាំទ្រ និងដើម្បីអប់រំលើកកម្ពស់ការយល់ដឹង និងការផ្លាស់ប្តូរអាកប្បកិរិយាទាក់ទងនឹងការអប់រំផ្លូវភេទគ្រប់ជ្រុងជ្រោយ តាមរយៈកម្មវិធីការពារសហគមន៍។ យុទ្ធសាស្រ្តទាំងអស់នេះត្រូវបានសម្របសម្រួលដើម្បីបញ្ជ្រាបការយល់ដឹងអំពីយេនឌ័រ ទប់ស្កាត់ការចម្លងមេរោគអេដស៍/ជំងឺអេដស៍ និងកាមរោគ រួមទាំងការចម្លងពីម្តាយទៅកូន បង្កើនលទ្ធភាពទទួលបានសេវា បង្កើនប្រាក់ចំណូល កាត់បន្ថយការមាក់ងាយ ការរើសអើង និងជួយសម្រួលដល់ការបង្កើនការគាំទ្រសហគមន៍ប្រកបដោយនិរន្តរភាព។




*កំពង់ឆ្នាំង កម្ពុជា។ អាជ្ញាធរម្នាក់កំពុងនិយាយក្នុងទិវាប្រយុទ្ធប្រឆាំងនឹងជម្ងឺអេដស៍*

ការធ្វើការងាររួមគ្នានេះផងដែរ យើងប្រើប្រាស់ជំនាញផ្លាស់ប្តូរទៅវិញទៅមក និងសហការរៀបចំផែនការ និងអនុវត្តផែនការដោគជ័យជាមួយសហគមន៍មូលដ្ឋាន។ លើសពីនេះ អង្គការឆេកបានបង្កើតឡើង និងជំរុញទំនាក់ទំនងដ៏រឹងមាំជាមួយក្រសួងកិច្ចការនារី ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល និងក្រសួងមហាផ្ទៃ។



*កំពង់ឆ្នាំង កម្ពុជា។ សិស្សប្រុសម្នាក់កំពុងនិយាយក្នុងទិវាប្រយុទ្ធប្រឆាំងនឹងជម្ងឺអេដស៍*

អ្នកពាក់ព័ន្ធសំខាន់ៗជាច្រើន ទាំងរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល បានចូលរួមដើម្បីទ្រទ្រង់កម្មវិធីនេះ។ អង្គការឆេក បានខិតខំកសាង និងរក្សាទំនាក់ទំនងយ៉ាងរឹងមាំ និងធ្វើសកម្មភាពជាមួយក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ គណៈកម្មាធិការគ្រប់គ្រងសុខភាពស្រុក មន្ទីរសុខាភិបាលខេត្ត និងអ្នកផ្តល់សេវាមូលដ្ឋាននៅក្នុងស្រុកប្រតិបត្តិការ។



*កំពង់ឆ្នាំង កម្ពុជា។ សិស្សស្រីម្នាក់កំពុងនិយាយក្នុងទិវាប្រយុទ្ធប្រឆាំងនឹងជម្ងឺអេដស៍*

# លទ្ធផលបានបង្ហាញឱ្យឃើញអំពីការសម្រេចបានជោគជ័យតាមសូចនាករខាងក្រោម៖

| សូចនាករគម្រោងក្នុងខែមិថុនា ឆ្នាំ២០២៤ | | | | | | |
|---|---|---|---|---|---|---|
| **សូចនាករ** | **មូលដ្ឋាន** | **ខែធ្នូ ២០២២** | **ខែកក្កដា ២០២៣** | **ធ្នូ ២០២៣** | **ខែកក្កដា ២០២៤** | **ការបកស្រាយ** |
| **គោលបំណងទី១៖ CSE ក្មេងជំទង់ (ការអប់រំផ្លូវភេទគ្រប់ជ្រុងជ្រោយ) មានភាពប្រសើរឡើង** | | | | | | |
| ចំនួនសាលារៀនដែលដាក់បញ្ចូល CSE នៅក្នុងកម្មវិធីសិក្សារបស់ពួកគេកើនឡើង ៧០% ។ | ៥៦% | ៥៩% | ៦៥% | ៧៥% | ៧៦% | ៧៦% នៃគ្រូបង្រៀន ៥៨នាក់ មកពី ២៥សាលា ក្នុងស្រុកចំនួន៤ បានរាយការណ៍ថា មាន CSE នៅក្នុងកម្មវិធីសិក្សារបស់សាលាពួកគេ ដែលមានការកើនឡើង ១% ពី ៧៥% ទៅ៧៦% ដល់ឆមាសចុងក្រោយ។ |
| ៧០% នៃក្មេងជំទង់ចែករំលែកចំណេះដឹងរបស់ពួកគេលើ CSE ជាមួយមិត្តភ័ក្តិរបស់ពួកគេ។ | ១២% | ១៥.៧% | ២១.១% | ៤៩% | ៥៣% | ២៩% នៃយុវវ័យក្នុងលទ្ធផលស្រាវជ្រាវ impact និង៧៨% នៃយុវវ័យ មកពីសហគមន៍ បានធ្វើការជជែកពិភាក្សាចែករំលែកចំណេះដឹង អំពី CSE ជាមួយមិត្តភក្តិរបស់ពួកគេ។ |
| **គោលបំណងទី២៖ ការប្រើប្រាស់សេវា SRHR ដោយក្មេងជំទង់ និង LGBTIQ មានការកើនឡើង** | | | | | | |
| ចំនួនអ្នកស្រឡាញ់ភេទដូចគ្នា ប្រើសេវាប្រឹក្សាផ្លូវចិត្ត មានការកើនឡើង ៥០%។ | 0% | ១១% | ៣២% | ៣៥% | ៤១% | ២៦% នៃអ្នកស្រឡាញ់ភេទដូចគ្នាចំនួន៩៣នាក់ បានប្រើប្រាស់សេវាសុខភាព ហើយក្នុងចំណោមនោះ ៤១% (១១/២៧) នៃអ្នកស្រលាញ់ភេទដូចគ្នាទទួលបានការប្រឹក្សាផ្លូវចិត្ត។ |
| ការធ្វើតេស្តរកមេរោគអេដស៍/កាមរោគ នៅក្នុងមណ្ឌលសុខភាពសហគមន៍កើនឡើង ៧០%។ | HIV: ក្មេងជំទង់: 0% LGBTIQ: ២៦% STI: ក្មេងជំទង់:១% LGBTIQ: ៣២% | HIV: ក្មេងជំទង់: ៣,៣% LGBTIQ: ៤៤% STI: ក្មេងជំទង់: ១,៣% LGBTIQ: ១៦,៧% | HIV: ក្មេងជំទង់: ១២% (២៤/២០៨) LGBTIQ: ២១% (១៩/៨៩) SIT: ក្មេងជំទង់: ១១% (២៣/២០៨) LGBTIQ: ២៤% (២១/៨៩) | HIV៖ ក្មេងជំទង់: ២៩,១៩% (៥៤/១៨៥) LGBTIQ: ២៧,៩៦% (៩៣/២៦) SIT: ក្មេងជំទង់: ២៧% LGBTIQ: ២៧,៣៨% (២៣/៨៤) | HIV: ក្មេងជំទង់: ៣៥% (១១៥/៣៣២) LGBTIQ: ៣៥% (៤៣/១២២) SIT: ក្មេងជំទង់: ៣៣% (១០៩/៣៣២) LGBTIQ: ៣៤% (៤១/១២២) | អត្រាយុវវ័យទទួលបានការធ្វើតេស្តឈាមរកមេរោគអេដស៍ និងការព្យាបាលកាមរោគបានកើនឡើង ដល់ឆមាសក្រោយចុង និងកម្រិតមូលដ្ឋាន។ (ទិន្នន័យបានមកពីការសិក្សា impact ការពិភាក្សាសហគមន៍ និងកិច្ចប្រជុំជាមួយ LGBT) |
| **គោលបំណងទី៣៖ នៅចុង ខែមិថុនា ឆ្នាំ២០២៤ អំពើហិង្សាយេនឌ័រ នៅក្នុងតំបន់គម្រោងបានថយចុះ** | | | | | | |
| ៩០% នៃសមាជិកក្រុមបុរស បានគោរពសិទ្ធិស្ត្រី។ | ៤៦% | ៦៧% | ៧៦% | ៨៣% | ៨៧,៩០% | ក្នុងចំណោមនោះមាន៖<br>• ៦៧%នៃក្រុមបុរសបានគោរពសិទ្ធិស្ត្រី។<br>• ការមិនអាចទទួលយកដាច់ខាតចំពោះការគំរាមកំហែង ឬការរំលោភបំពានដោយប្រើពាក្យសម្តី ពីដៃគូដែលប្រើប្រាស់ប្រដាប់អាវុធ និងឧបករណ៍ផ្សេងទៀតមានចំនួន ៩៤%។<br>• ៩៣% នៃករណីអំពើហិង្សាយេនឌ័រទាំងអស់ដែលកើតឡើង គឺមិនមានការស្តីបន្ទោសទៅលើស្ត្រី ហើយវាមិនមែនជាកំហុសរបស់ស្ត្រី។ ប្តីមិនមានសិទ្ធិវាយប្រពន្ធពេលនាងមានកំហុស គឺមាន៩៨% ។ |
| ៩០% នៃជនរងគ្រោះពីអំពើហិង្សាផ្អែកលើយេនឌ័រ រាយការណ៍ថារស់នៅដោយគ្មានអំពើហិង្សាយ៉ាងហោចណាស់ ១២ ខែ។ | ៦៧% | ៥៦% | ៧៤% | ៧៨,៣% | ៨៤% | ៨៤% នៃជនរងគ្រោះពីអំពើហិង្សាផ្អែកលើយេនឌ័រ ដែលមានចំនួន១១៣នាក់ បានរាយការណ៍ថា ពួកគេរស់នៅដោយសេរី និងរួចផុតពីអំពើហឹង្សា។ |

# គម្រោង៖ ការឆ្លើយតបនឹងសុខភាពសហគមន៍សម្រាប់អ្នករស់នៅជាមួយមេរោគអេដស៍ យុវជន និងអំពើហិង្សាផ្អែកលើភេទ ដំណាក់កាលទី២

បញ្ហាប្រឈមផ្នែកសុខភាពក្នុងប្រទេសកម្ពុជានៅតែត្រូវបានបង្រួបបង្រួមដោយធនធាននៅមានកម្រិត និង ដោយបន្ទុកនៃជំងឺដែលត្រូវបានសម្គាល់ដោយ រោគរាតត្បាត ប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម។

សុខភាព និងការអប់រំនៅតែជាបញ្ហាប្រឈមដ៏សំខាន់ និងជាអទិភាពនៃការអភិវឌ្ឍន៍សម្រាប់កម្ពុជា។ យោងតាមការស្ទង់មតិប្រជាសាស្ត្រ និងសុខភាពកម្ពុជាឆ្នាំ ២០២១-២០២២ បង្ហាញថាតិចជាង ១%នៃស្ត្រីដែលមានអាយុពី ១៥-៤៩ឆ្នាំមានដៃគូផ្លូវភេទពីរ ឬច្រើន ឬបានរួមភេទជាមួយមនុស្សដែលមិនមែនជាស្វាមី ឬរស់នៅជាមួយពួកគេក្នុងរយៈពេល១២ខែ។ ក្នុងចំណោមស្ត្រីដែលមានដៃគូរួមភេទពីរ ឬច្រើននាក់ក្នុងរយៈពេល១២ខែមុនការស្ទង់មតិ ៨%បានរាយការណ៍ថាបានប្រើប្រាស់ស្រោមអនាម័យអំឡុងពេលរួមភេទចុងក្រោយរបស់ពួកគេ។ ស្ទើរតែពាក់កណ្តាល(៤៧%)នៃស្ត្រីដែលបានរួមភេទក្នុងរយៈពេល១២ខែចុងក្រោយជាមួយមនុស្សដែលមិនមែនជាស្វាមីរបស់ពួកគេ ឬរស់នៅជាមួយពួកគេបានប្រើប្រាស់ស្រោមអនាម័យក្នុងកំឡុងពេលរួមភេទ។ ២%នៃបុរសដែលមានអាយុពី ១៥-៤៩ឆ្នាំ បានរាយការណ៍ថាមានដៃគូរួមភេទពីរ ឬច្រើនក្នុងរយៈពេល១២ខែមុនការស្ទង់មតិ ហើយ៤%មានទំនាក់ទំនងផ្លូវភេទក្នុងរយៈពេល១២ខែចុងក្រោយជាមួយនឹងមនុស្សដែលមិនមែនជាប្រពន្ធរបស់ពួកគេ ឬរស់នៅជាមួយពួកគេ។ ក្នុងចំណោមបុរសដែលមានដៃគូរួមភេទពីរ ឬច្រើននាក់ ៣២%ប្រើស្រោមអនាម័យកំឡុងពេលរួមភេទចុងក្រោយរបស់ពួកគេ។ បុរស ៧៦%ដែលបានរួមភេទក្នុងរយៈពេល១២ខែចុងក្រោយជាមួយមនុស្សដែលមិនមែនជាស្វាមី ឬរស់នៅជាមួយពួកគេបានប្រើស្រោមអនាម័យក្នុងកំឡុងពេលរួមភេទចុងក្រោយ។

ចំនុចគួរឱ្យកត់សម្គាល់ជាងនេះទៅទៀត គឺវាមានការថយចុះនៃការយល់ដឹងជាក់ស្តែងអំពីមេរោគអេដស៍ក្នុងចំណោមយុវជន ដោយរបាយការណ៍បង្ហាញត្រឹមតែ ២៣%នៃស្ត្រីវ័យក្មេង និង ២៧%នៃបុរសវ័យក្មេងដែលមានការយល់ដឹងពិតប្រាកដអំពីមេរោគអេដស៍/ជំងឺអេដស៍(បើធៀបនឹងឆ្នាំ២០១៤, ៣៨%នៃស្ត្រីវ័យក្មេង និង ៤៦%នៃបុរសវ័យក្មេង)។

ចំណុចសំខាន់បំផុតគឺថា កម្ពុជាត្រូវបង្កើនការធ្វើតេស្តរកមេរោគអេដស៍ពី ៨៦% ទៅ ៩៥% នៅឆ្នាំ២០២៥។ ក្នុងករណីនេះ កម្ពុជាចាំបាច់ត្រូវដាក់ចេញនូវយុទ្ធសាស្រ្តបង្ការដ៏ទូលំទូលាយ និងពហុវិស័យប្រកបដោយប្រសិទ្ធិភាព។ នៅពេលដែលអត្រានៃការធ្វើតេស្តរកមេរោគអេដស៍កើនឡើងដល់ ៩៥% ពី ៨៦% ប្រទេសកម្ពុជានឹងឈានដល់គោលដៅបញ្ចប់ជំងឺអេដស៍ ព្រោះគោលដៅទី២ និងទី៣ សម្រេចបាន ៩៥% ហើយ ៩៩% និង ៩៨%។

បច្ចុប្បន្ននេះ ដោយមានការគាំទ្រនិងតស៊ូមតិ ក្រសួងមហាផ្ទៃយល់ព្រមដាក់បញ្ចូលមេរោគអេដស៍/ជំងឺអេដស៍ជាចំណុចទី១០ នៃគោលនយោបាយភូមិឃុំមានសុវត្ថិភាព។ លើសពីនេះ កិច្ចខិតខំប្រឹងប្រែងនឹងត្រូវបានធ្វើឡើងដើម្បីបញ្ជ្រាបទិដ្ឋភាពនៃការឆ្លើយតបយេនឌ័រ ទៅក្នុងកម្មវិធីសហគមន៍ និងសកម្មភាពមេរោគអេដស៍ដែលគ្រប់គ្រងដោយ PAC/PAS/GoC។

កម្មវិធីនេះបានជះឥទ្ធិពលយ៉ាងខ្លាំងដល់អ្នកទទួលផលដោយពង្រឹងចំណេះដឹង និងការយល់ដឹងរបស់ពួកគេអំពីអំពើហិង្សាលើយេនឌ័រ និងបញ្ហាសុខភាពយុវជន ធ្វើឱ្យអ្នករស់រានមានជីវិតពីអំពើហិង្សាលើយេនឌ័រកាន់តែមានទំនុកចិត្តក្នុងការស្វែងរកសេវាគាំទ្រ ហើយអាជ្ញាធរមូលដ្ឋានកាន់តែមានទំនុកចិត្តក្នុងការចូលរួមជាមួយសហគមន៍ និងយុវជន ការរាយការណ៍/បញ្ជូនករណីអំពើហិង្សាលើយេនឌ័រដើម្បីផ្តន្ទាទោស ឬការអញ្ជើញយុវជនឱ្យចូលរួមកិច្ចប្រជុំ។ ក្រៅពីនេះ អង្គការធេកបានភ្ជាប់ជាមួយបណ្តាញមួយចំនួនដើម្បីធ្វើការតស៊ូមតិទៅលើសិទ្ធិស្ត្រី និងចែករំលែកមេរៀនរបស់ពួកគេក្នុងការអនុវត្តគម្រោងដើម្បីជាប្រយោជន៍ដល់ស្ត្រីដែលធ្លាប់ឆ្លងកាត់អំពើហិង្សាលើយេនឌ័រ។




| សូចនាករទី១)៖ តម្លៃគោលដៅដែលបានយល់ព្រមនៅចុងបញ្ចប់នៃគម្រោង | តម្លៃមូលដ្ឋាននៅពេលចាប់ផ្តើមគម្រោង (ខែ/ឆ្នាំ)៖ សីហា-២០២២ | តម្លៃបណ្តោះអាសន្នណាមួយ (ខែ/ឆ្នាំ)៖ មិថុនា-២០២៣ | តម្លៃបណ្តោះអាសន្នណាមួយ (ខែ/ឆ្នាំ)៖ ធ្នូ-២០២៣ | តម្លៃបណ្តោះអាសន្នណាមួយ (ខែ/ឆ្នាំ)៖ មិថុនា-២០២៤ | តម្លៃបច្ចុប្បន្ន (ខែ/ឆ្នាំ)៖ គម្រោង CHR បានធ្វើការសិក្សាអំពីផលប៉ះពាល់នៅខែមិថុនា ឆ្នាំ២០២៤ ដោយមានជនរងគ្រោះដោយអំពើហិង្សាយេនឌ័រ ចំនួន៧៩នាក់ អ្នកផ្ទុកមេរោគអេដស៍ ចំនួន៨០នាក់ និងយុវវ័យ ចំនួន៥៤នាក់ នៅក្នុងស្រុកចំនួន២ ដើម្បីវាស់ស្ទង់គម្រោងការងារទាក់ទងនឹងសូចនាករ។ |
|---|---|---|---|---|---|
| **គោលបំណងនៃគម្រោងទី១៖** ការទទួលបានសេវាពាក់ព័ន្ធសម្រាប់អ្នកដែលមានហានិភ័យ ឬជនរងគ្រោះពីអំពើហិង្សាយេនឌ័រ អ្នកជំងឺអេដស៍/ជំងឺអេដស៍ និងយុវជនមានភាពប្រសើរឡើង។ | | | | | |
| យ៉ាងហោចណាស់ ៧០% នៃជនរងគ្រោះពីអំពើហិង្សាយេនឌ័រ បានទទួលបានការគាំទ្រពីអាជ្ញាធរ និងច្បាប់ និងសង្គមរបស់ពួកគេ។ | ៣៧% | ៤៥% | ៤៦% | ៥១% | ឆ្លើយតបទៅនឹងសូចនាករដូចខាងក្រោម:<br>១. បានទទួលការគាំទ្រពីអាជ្ញាធរមូលដ្ឋាន (៥៦%)<br>២. បានទទួលការគាំទ្រពីសហគមន៍មូលដ្ឋាន (៦១%)<br>៣. ទទួលបានការគាំទ្រពីសង្គមសេជនក្នុងស្រុក (៣៥%) |
| ករណីសិក្សា ចំនួន៤ បានធ្វើឡើងជារៀងរាល់ឆ្នាំ ទាក់ទងនឹងការថយចុះអំពើហិង្សាក្នុងគ្រួសារ ដោយមានការអន្តរាគមន៍ពីគម្រោង | ០ | ០ | ០ | ០ | |
| **គោលបំណងនៃគម្រោងទី២៖** ស្ថានភាពសុខភាពរបស់អ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ មានភាពប្រសើរឡើង ឬមានស្ថេរភាព។ | | | | | |
| យ៉ាងហោចណាស់ ៨០% នៃអ្នកផ្ទុកមេរោគអេដស៍ ដែលទទួលបានការគាំទ្រដោយគម្រោង បានប្រកាន់ខ្ជាប់ ART adherence។ | ៧៩% | ៨៦% | ៨៨% | ៩០% | ឆ្លើយតបទៅនឹងសូចនាករដូចខាងក្រោម:<br>១. អ្នកផ្ទុកមេរោគអេដស៍មានសុខភាពល្អ និងមិនដែលកើតជំងឺផ្សេងៗ (៦១%)<br>២. អ្នកផ្ទុកមេរោគអេដស៍មានថាមពលដើម្បីធ្វើការរកប្រាក់ចំណូល (ប្រើថ្នាំ ARV ជាប្រចាំ) (១០០%)<br>៣. មិនដែលប្តូរថ្នាំ(១០០%)<br>៤. ប្រើមណ្ឌលសុខភាព (ARV) ដោយការណាត់ជួបនៅមន្ទីរពេទ្យ (៩៩%) |
| | | | | | *ចំណាំ៖ មានតែអ្នកផ្ទុកមេរោគអេដស៍ចំនួន ១៧នាក់ ប៉ុណ្ណោះដែលដឹងថា Viroload < 1000 នៅក្នុងឈាមរបស់គេ។* |
| ករណីសិក្សាចំនួន៤បានសរសេរឡើងជារៀងរាល់ឆ្នាំ ទាក់ទងនឹងស្ថានភាពសុខភាពបានប្រសើរឡើង ឬមានស្ថិរភាព នៃអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ | ០ | ១ | ០ | ០ | |
| **គោលបំណងនៃគម្រោងទី៣៖** លទ្ធភាពទទួលបានសម្រាប់យុវវ័យ ចំពោះសេវាកម្មពាក់ព័ន្ធ មានភាពប្រសើរឡើង។ | | | | | |
| លទ្ធភាពទទួលបានសម្រាប់យុវវ័យ ដើម្បីធ្វើតេស្តរកមេរោគអេដស៍/ជំងឺអេដស៍ និងជំងឺកាមរោគផ្សេងទៀត មានភាពប្រសើរឡើងនៅក្នុងតំបន់គម្រោង។ | ការធ្វើតេស្តរក មេរោគអេដស៍៖ ៥,៧% ការធ្វើតេស្ត និងព្យាបាលជំងឺកាមរោគ៖ ៦,២% | ការធ្វើតេស្តរក មេរោគអេដស៍៖ ២០% ការធ្វើតេស្ត និងព្យាបាលជំងឺកាមរោគ៖ ២៥% | ការធ្វើតេស្តរក មេរោគអេដស៍៖ ៣២% ការធ្វើតេស្ត និងព្យាបាលជំងឺកាមរោគ៖ ២៧% | ការធ្វើតេស្តរក មេរោគអេដស៍៖ ៣៤% ការធ្វើតេស្ត និងព្យាបាលជំងឺកាមរោគ៖ ៣០% | យុវវ័យទទួលបានVCCTសម្រាប់ការធ្វើតេស្តរកមេរោគអេដស៍ កើនឡើងដល់២៨% ហើយការព្យាបាលជំងឺកាមរោគ កើនឡើងដល់ ២៤% នៅកម្រិតមូលដ្ឋាន។ |

# ករណីសិក្សា

## ពីអ្នករស់រានមានជីវិតពីស្ត្រីរស់នៅជាមួយជំងឺអេដស៍ និងហិង្សា ទៅជាប្រធានក្រុមស្ត្រី

មុនពេល ឈុនលី ស្វែងរកការប្រឹក្សាពីអង្គការឆេក អ្នកស្រី និងកូនៗទាំងបីនាក់បានទទួលរងការទទួលរងនូវភាពធ្ងន់ធ្ងរនៃការលំបាករបស់ប្តី និងផ្លូវភេទ។ ជាម្តាយដែលរស់នៅជាមួយមេរោគអេដស៍និងស្វាមី បានជួបជាមួយមេភូមិ និងអ្នកសម្របសម្រួលស្រុកអង្គការឆេក ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលមួយចំនួនស្តីពីការផ្លាស់ប្តូរអាកប្បកិរិយាឆ្ពោះទៅរកអំពើការលុបបំបាត់ហិង្សាលើយេនឌ័រ។ នេះបាននាំឱ្យមានការផ្លាស់ប្តូរយ៉ាងសំខាន់ក្នុងការចែករំលែកតួនាទីនៅក្នុងគ្រួសារហើយគ្មានអំពើហិង្សាណាមួយត្រូវបានរាយការណ៍ចាប់តាំងពីទទួលបានវគ្គបណ្តុះបណ្តាលនេះមក។ ឈុនលី ជាស្ត្រីក្នុងចំណោមស្ត្រីរាប់រយនាក់ដែលស្វែងរកការគាំទ្រពីអង្គការឆេក ដែលជាអង្គការសិទ្ធិស្ត្រីដឹកនាំ និងធ្វើការដើម្បីការពារ និងផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងកុមារីដែលបានទទួលបានការគាំពារនៅក្នុងប្រទេសកម្ពុជា តាមរយៈសេវាសុខភាព និងការអប់រំ។

អ្នកស្រីឈ្មោះ ឈុនលី អាយុ៤៦ឆ្នាំ។ អ្នកស្រីរស់នៅជាមួយកូន៣នាក់នៅភូមិត្នោត២ ឃុំព្រែករំដេង ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ជីវភាពគ្រួសាររបស់អ្នកស្រីមិនសូវសម្បូរសប្បាយនោះទេ ដោយសារការអប់រំប្តីរបស់អ្នកស្រីនៅមានកម្រិត ហើយតែងតែស្រែកដាក់អ្នកស្រីដោយមិនខ្មាស់អៀនអ្នកដ៏ទៃក្នុងសហគមន៍។ គាត់គិតថាគាត់ជាមេគ្រួសារ និងរកប្រាក់ចិញ្ចឹមជីវិតប្រចាំថ្ងៃ ដូច្នេះគាត់មានសិទ្ធិធ្វើបាបអ្នកស្រី និងកូនដែលមិនស្តាប់គាត់។ ពេលមានលុយបន្តិចបន្តួច គាត់តែងតែផឹកស្រាស្រវឹង ហើយប្រើពាក្យមិនសមរម្យគម្រាមប្រើហិង្សាក្នុងគ្រួសារ។ អ្នកស្រីតូចចិត្តខ្លាំងហើយក៏មិនមានសុខភាពល្អដែរ ដោយសារមេរោគអេដស៍ និងប្រាក់ចំណូលទាប។

នៅឆ្នាំ២០២៣ មេភូមិ និងអ្នកសម្របសម្រួលស្រុកអង្គការឆេក បានអញ្ជើញប្តីប្រពន្ធទាំង២ឱ្យចូលរួមប្រជុំ ហើយដាក់បញ្ចូលក្នុងក្រុមសមាជិកក្រុមស្ត្រី និងបុរស។ ចាប់តាំងពីពេលនោះមក ពួកគាត់ទាំងពីរតែងបានទទួលការអប់រំ និងការប្រឹក្សាអំពីអំបើហិង្សាលើយេនឌ័រ និងអ្នកសម្របសម្រួលស្រុករបស់អង្គការឆេក។ ក្នុងកិច្ចប្រជុំពីរខែរបស់ក្រុមស្ត្រី និងបុរស ដែលសម្របសម្រួលដោយអ្នកសម្របសម្រួលស្រុក និង អង្គការដៃគូរ អ្នកស្រីត្រូវបានជ្រើសរើសដោយសមាជិកក្រុមឱ្យធ្វើជាប្រធានក្រុមស្ត្រី ដើម្បីរៀបចំកិច្ចប្រជុំ និងចែករំលែកនូវអ្វីដែលពួកគេបានរៀន និងទទួលបានវគ្គបណ្តុះបណ្តាលពីអង្គការឆេក។ អ្នកស្រីត្រូវបានអញ្ជើញឱ្យចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីអំពើហិង្សារលើយេនឌ័រ សិទ្ធិស្ត្រី និងសមភាពយេនឌ័រ ដែលបណ្តុះបណ្តាលដោយលោក ប៊ុតលីម មន្ត្រីគម្រោងជាន់ខ្ពស់។

លទ្ធផលនៃការប្រជុំ និងការបណ្តុះបណ្តាល ចំណេះដឹងទាំងផ្នែកអំពើហិង្សាលើយេនឌ័រ សិទ្ធិយេនឌ័រ និងស្ត្រីបានកើនឡើង ហើយពួកគេបានអនុវត្តចំណេះដឹងទាំងនេះក្នុងជីវភាពប្រចាំថ្ងៃរបស់ពួកគេ។ ផ្នត់គំនិត និងអាកប្បកិរិយារបស់ប្តីប្រពន្ធមួយគូនេះបានផ្លាស់ប្តូរ ពួកគាត់បានចែករំលែកនូវទំនួលខុសត្រូវក្នុងការងារផ្ទះ ហើយហ៊ានពិភាក្សាដោយបើកចំហរវាងអ្នកស្រី និងប្តី ពួកគាត់តែងតែស្តាប់គ្នាទៅវិញទៅមក ហើយលើសពីនេះទៀត សូម្បីតែពួកគាត់បានជជែកគ្នាយ៉ាងខ្លាំង ប៉ុន្តែមិនបាននាំឱ្យកើតជាអំពើហិង្សាក្នុងគ្រួសារទេ។ ចាប់តាំងពីពេលនោះមក អ្នកស្រីសប្បាយចិត្តខ្លាំងណាស់ ហើយអ្នកស្រីបានរាយការណ៍ថាអ្នកស្រី និងកូនៗរបស់អ្នកស្រីរស់នៅដោយគ្មានអំពើហិង្សា។



ដោយសារតែអ្នកស្រីជាអ្នកដឹកនាំក្រុមស្ត្រី អ្នកស្រីបានដឹកនាំកិច្ចប្រជុំក្រុមស្ត្រី និងចែករំលែកចំណេះដឹងអំពីអ្វីដែលអ្នកស្រីបានរៀនអំពីការបណ្តុះបណ្តាល និងបទពិសោធន៍ល្អដើម្បីបញ្ឈប់អំពើហិង្សាដល់សមាជិកក្រុមផ្សេងទៀតក្នុងអំឡុងពេលប្រជុំ ហើយក៏បានអន្តរាគមន៍ផ្តល់ការអប់រំ GBV ការផ្តល់ប្រឹក្សាដល់ស្ត្រីដទៃទៀតនៅក្នុងសហគមន៍ដែលទទួលរងអំពើហិង្សា និងធ្វើការបញ្ជូនស្ត្រី ដែលរស់រានមានជីវិតដើម្បីទទួលបាននូវសេវាជំនួយក្នុងស្រុកដូចជា ការថែទាំសុខភាព និងសេវាផ្លូវច្បាប់។ អ្នកស្រីតែងតែណែនាំដល់ស្ត្រីដទៃទៀតក្នុងក្រុមដែលយើងជាស្ត្រី យើងត្រូវក្លាហានហ៊ានពិភាក្សាជាមួយស្វាមីរបស់យើងអំពីសមភាពយេនឌ័រ និងសិទ្ធិស្ត្រី ជាពិសេសផលប៉ះពាល់នៃអំពើហិង្សា ហើយប្រើពាក្យឱ្យសមរម្យសម្រាប់ការរស់នៅជាប្រចាំថ្ងៃ ព្រោះវាជាមធ្យោបាយដ៏ល្អក្នុងការបញ្ឈប់អំពើហិង្សាក្នុងគ្រួសារ។ ជាចុងបញ្ចប់ អ្នកស្រីបានថ្លែងអំណរគុណចំពោះម្ចាស់ជំនួយតាមរយៈអង្គការឆេក ដែលបានគាំទ្រកម្មវិធីទប់ស្កាត់អំពើហិង្សាពីដៃគូជិតស្និតក្នុងគ្រួសារ ហើយអ្នកស្រីបាននិយាយថា សមាជិកក្រុមរបស់គាត់អាចពិភាក្សា និងដោះស្រាយបញ្ហា ទាំងផ្លូវកាយ និងផ្លូវចិត្តទាក់ទងនឹងអំពើហិង្សារ និងបានអប់រំ សិទ្ធិយេនឌ័រ និងស្ត្រីនៅក្នុងសហគមន៍ ជាពិសេសប្តីរបស់គាត់បានផ្លាស់ប្តូរផ្នត់គំនិត និងអាកប្បកិរិយាពីអវិជ្ជមានទៅជាវិជ្ជមានដោយគ្មានអំពើហិង្សា។ អ្នកស្រីសូមជូនពរម្ចាស់ជំនួយ និងបុគ្គលិកអង្គការឆេក ជួបតែសំណាងល្អ និងសុខភាពល្អគ្រប់ពេលវេលា ដើម្បីអាចបន្តគម្រោងផ្តល់ការអប់រំ និងជួយបញ្ឈប់អំពើហិង្សាលើស្ត្រី និងកុមារីនៅកម្ពុជា។

# ការប្រកាន់ខ្ជាប់ដ៏ល្អរបស់អ្នកស្រី ខេន វ៉ាន់

អ្នកស្រី ខេន វ៉ាន់ អាយុ៤៣ឆ្នាំ រស់នៅភូមិក្រាំងស្រម៉រ ឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង មានកូនប្រុសម្នាក់ និងកំពុងរស់នៅជាមួយមេរោគអេដស៍តាំងពីឆ្នាំ១៩៩៧។ ប្តីអ្នកស្រីជាទាហានខ្មែរក្រហមមកពីស្រុកសំឡូត គាត់បានធ្លាក់ខ្លួនឈឺ និងស្លាប់នៅឆ្នាំ២០០០ ដោយសារមេរោគអេដស៍។ បន្ទាប់ពីប្តីរបស់អ្នកស្រីបានស្លាប់ អ្នកស្រីរស់នៅជាមួយកូន និងក្មួយប្រុសជាមួយនឹងការរើសអើង និងមាក់ងាយ ហើយស្ថានភាពរស់នៅរបស់អ្នកស្រីលំបាកទាំងសុខភាព ជាមួយការអស់សង្ឃឹម។ ទោះបីជាសុខភាពអ្នកស្រីមិនល្អយ៉ាងណាក៏ដោយ អ្នកស្រីបានព្យាយាមធ្វើការដើម្បីប្រាក់(អ្នកបម្រើ) ក្នុងការផ្គត់ផ្គង់តម្រូវការជាប្រចាំ ដោយទទួលបាន៥ដុល្លារក្នុងមួយថ្ងៃ។



អ្នកស្រីបានចូលរួមជាមួយគម្រោងតាំងពីឆ្នាំ២០២២ តាមរយៈ CHVs ដែលបានមកសួរសុខទុក្ខអ្នកស្រី និងផ្តល់ការអប់រំស្តីពី Art Adherence។ ក្រោយពីអ្នកស្រីទទួលបានចំណេះដឹងនេះ ហើយបានផ្លាស់ប្តូរការប្រកាន់ខ្ជាប់សម្រាប់ការរស់នៅ និងអនុវត្តការប្រកាន់ខ្ជាប់ល្អ។

អ្នកស្រីសង្កេតឃើញថា អ្នកស្រីមានសុខភាពល្អ ដោយមិនងាយឆ្លងជំងឺផ្សេងៗ អ្នកស្រីមានកម្លាំងក្នុងការធ្វើការងារ ដើម្បីបង្កើនប្រាក់ចំណូល។ ក្រៅពីធ្វើជាអ្នកបម្រើ អ្នកស្រីក៏ចិញ្ចឹមមាន់ ទា និងដាំដំណាំ ដើម្បីប្រាក់ចំណូលបន្ថែមសម្រាប់ចញ្ចឹមជីវិត ហើយសម្រាប់កូនទៅរៀន។ ដោយសារអ្នកស្រីមានសុខភាពល្អ និងភាពធន់ អ្នកស្រីសង្កេតឃើញថា អ្នកជិតខាងមានការផ្លាស់ប្តូរច្រើនដោយការទៅសួរសុខទុក្ខអ្នកស្រី និងផ្តល់អាហារមួយចំនួនដោយមានការបរិច្ចាកខ្លះៗ ហើយក៏មានការគាំទ្រពីអាជ្ញាធរមូលដ្ឋាន។ អ្នកស្រីមានអារម្មណ៍សប្បាយរីករាយ រំភើប និងមានទំនុកចិត្ត ក៏ដូចជាភាពក្លាហានក្នុងការប្រឈមមុខនឹងសហគមន៍ ជាពិសេសអ្នកស្រីបានចែករំលែកនូវការអនុវត្តល្អដ៏សកម្ម ទៅកាន់ចំពោះអ្នកផ្ទុកមេរោគអេដស៍ផ្សេងទៀតនៅក្នុងសហគមន៍។




**រូបភាពតំណាង**

បច្ចុប្បន្ន អ្នកស្រី ខេន វ៉ាន់ រស់នៅយ៉ាងកក់ក្តៅជាមួយកូនប្រុស និងក្មួយប្រុស ហើយស្ថានភាពរស់នៅរបស់អ្នកស្រីក៏ប្រសើរឡើង និងមានទំនាក់ទំនងល្អ និងការប្រាស្រ័យទាក់ទងល្អជាមួយសហគមន៍។ អ្នកស្រីក៏មានប័ណ្ណសមធម៌ដែលចេញដោយមេឃុំ ដើម្បីទទួលសេវាថែទាំសុខភាព និងព្យាបាលដោយមិនគិតប្រាក់។



# អរគុណម្ចាស់ជំនួយ

យើងអាចអនុវត្តសកម្មភាពរបស់យើងដោយជោគជ័យក្នុងតំបន់គោលដៅ ដោយមានការគាំទ្រពីម្ចាស់ជំនួយរបស់យើង។ យើងសូមថ្លែងអំណរគុណចំពោះម្ចាស់ជំនួយដូចជា Bread for the World (BfDW) និង MISEREOR ចំពោះការគាំទ្រជាបន្តបន្ទាប់របស់ពួកគាត់ ចំពោះគម្រោងរបស់យើង និងមូលនិធិ UN Trust Fund ដែលអង្គការធេក បានទទួលជំនួយសម្រាប់ការតស៊ូមតិរបស់ CEDAW ដើម្បីបញ្ចប់អំពើហិង្សាលើស្ត្រី គម្រោងនៃវដ្តជំនួយ ចំនួន២៥ របស់ខ្លួន។

Bread of the World (BfdW) គឺជាទីភ្នាក់ងារអភិវឌ្ឍន៍សកលយ៉ាងសកម្ម និងជំនួយសង្គ្រោះរបស់ប្រទេសអាល្លឺម៉ង់។ អង្គការនេះធ្វើការ ដើម្បីផ្តល់សិទ្ធិអំណាចដល់ជនក្រីក្រ និងជនទន់ខ្សោយ ដើម្បីបង្កើនជីវភាពរស់នៅរបស់ពួកគេ រួមទាំងសន្តិសុខស្បៀង ការលើកកម្ពស់សុខភាព ការអប់រំ និងការគោរពសិទ្ធិមនុស្ស។

MISEREOR គឺជាអង្គការសាសនាកាតូលិកអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍។ MISEREOR ជាអង្គការ គាំទ្រសង្គមដូចជា៖ ជនក្រីក្រ អ្នកជំងឺ អ្នកអត់ឃ្លាន និងអ្នកជួបការលំបាក។ ព្រមទាំងបំពេញតម្រូវការជាមូលដ្ឋាន ដូចជា សន្តិសុខស្បៀង។ អង្គការក៏ជួយធានាលើកតម្កើងសិទ្ធិមនុស្សផងដែរ ហើយបានត្រួសត្រាយផ្លូវសម្រាប់ប្រជាពលរដ្ឋ ដែលពាក់ព័ន្ធក្នុងការរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ។

UN Trust Fund ត្រូវបានបង្កើតឡើងដោយមហាសន្និបាតអង្គការសហប្រជាជាតិ ក្នុងឆ្នាំ១៩៩៦។ វាគឺជាការផ្តល់ជំនួយជាសកល ពហុភាគី យន្តការដែលគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងជាតិ ដើម្បីទប់ស្កាត់ និងបញ្ចប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី។ មូលនិធិជឿទុកចិត្ត អង្គការសហប្រជាជាតិ បានគ្រប់គ្រងក្នុងនាមជាប្រព័ន្ធ អង្គការសហប្រជាជាតិ ដោយអង្គភាពអង្គការសហប្រជាជាតិសម្រាប់សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី (UN Women) ដែលផ្តល់នូវមូលដ្ឋានគ្រឹះ ស្ថាប័នដ៏រឹងមាំ និងការគាំទ្រគោលដៅ តាមរយៈការិយាល័យក្នុងតំបន់ ពហុប្រទេស និងប្រទេសទាំងនោះ។

# របាយការណ៍ហិរញ្ញវត្ថុ (កក្កដា-២០២៣ ដល់ មិថុនា-២០២៤)

| ល | គម្រោង | ម្ចាស់ជំនួយ | ចំណូល | ចំណាយ |
| --- | --- | --- | --- | --- |
| ១ | គម្រោង៖ ការផ្តល់អំណាចដល់យុវជន សម្រាប់សុខភាពផ្លូវភេទ សុខភាពបន្តពូជ និងសិទ្ធិ និងការចូលរួមក្នុងសហគមន៍/ការតស៊ូមតិ សម្រាប់ការអប់រំក្នុងសហគមន៍ ដើម្បីបញ្ចប់អំពើហិង្សាលើស្ត្រី | BfdW | $ ៣៧,៤៨៩.៨០ | $ ២៩០,៥១៤.៤១ |
| | | UNTF | $ ២០៦,១៦១.១៥ | |
| ២ | គម្រោង៖ ការឆ្លើយតបនឹងសុខភាពសហគមន៍ សម្រាប់អ្នកផ្ទុកមេរោគអេដស៍ យុវជន និងអំពើហិង្សាយេនឌ័រ ដំណាក់កាលទី២ | MISEREOR | $ ៥៦,៦២៦.៦០ | $ ៦៩,១៥១.៩៣ |
| ៣ | កម្មវិធីស្រាវជ្រាវ | NGO-CEDAW | $ ២,៧០៣.៩១ | $ ១,៧៦៤.០៥ |
| ៤ | ការស្វែងរកប្រាក់ចំណូល | CHEC | $ ១៣.២៨ | $ ៤៨៤.២៣ |
| | | **ថវិកាសរុប** | $ ៣០២,៩៩៤.៧០ | $ ៣៦១,៩១៤.៦២ |

# របាយការណ៍ហិរញ្ញវត្ថុ (កក្កដា-២០២៣ ដល់ មិថុនា-២០២៤)







គម្រោង៖ ការផ្តល់អំណាចដល់យុវជន សម្រាប់សុខភាពផ្លូវភេទ សុខភាពបន្តពូជ និងសិទ្ធិ និងការចូលរួមក្នុងសហគមន៍/ការតស៊ូមតិ សម្រាប់ការអប់រំក្នុងសហគមន៍ ដើម្បីបញ្ចប់អំពើហិង្សាលើស្ត្រី

គម្រោង៖ ការឆ្លើយតបនឹងសុខភាពសហគមន៍ សម្រាប់អ្នកផ្ទុកមេរោគអេដស៍ យុវជន និងអំពើហិង្សាយេនឌ័រ ដំណាក់កាលទី២

កម្មវិធីស្រាវជ្រាវ

ការស្វែងរកប្រាក់ចំណូល

# រចនាសម្ព័ន្ធអង្គការឆេក ឆ្នាំ២០២៤



CHEC

# ជួយសហគមន៍អោយជួយខ្លួនឯង

## ទំនាក់ទំនងតាម

+៨៥៥ ១២ ៦២០ ៦០៨ or +៨៥៥ ៧០ ៦២០ ៦០៨

chec@online.com.kh

www.checcam.org

ផ្ទះលេខ#6S, ផ្លូវលេខ ២៦៥, សង្កាត់ទឹកល្អក់៣,
ខណ្ឌទួលគោក, ភ្នំពេញ, កម្ពុជា, P.O.Box 636

## បណ្ដាញសង្គមអង្គការឆេក

CHEC Organization

chec_cambodia

@CHECCambodia

@CHECCambodia